ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

សំណុំរឿងព្រហ្មទណ្ឌលេខៈ១៨១៩ អ.ក
ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២២
សាលក្រមលេខៈ ៨០ -ថ-
ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៣

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តកណ្តាល**

បានបើកសវនាការជំនុំជម្រះជាសាធារណៈនាថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣
វេលាម៉ោង០៨ និង ៣០នាទីព្រឹក ដោយមានសមាសភាពដូចតទៅៈ

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមជំនុំជម្រះនៃសាលាដំបូងខេត្តកណ្តាល

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីសវនាការនៃសាលាដំបូងខេត្តកណ្តាល

**មេធាវី**

លោក [redacted] ជាមេធាវីការពារក្តីឲ្យជនជាប់ចោទ [redacted] ស្រីនិត
លោក [redacted] ជាមេធាវីការពារក្តីឲ្យជនជាប់ចោទ [redacted] ស្រីនិត
លោក [redacted] ជាមេធាវីការពារក្តីឲ្យដើមបណ្តឹងរដ្ឋប្បវេណី [redacted] សិទ្ធី

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខៈ **១៨១៩ អ.ក** ចុះថ្ងៃទី០២ ខែធ្នូ២០ឆ្នាំ ២២ ដែលមានជនជាប់ចោទឈ្មោះ [redacted] **ស្រីនិត** ភេទស្រី អាយុ ២២ឆ្នាំ ជនជាតិខ្មែរ មុខរបរវេរលុយទូរស័ព្ទម៉ាន់នី មានទីកន្លែងកំណើត [redacted] ខេត្តកំពង់ចាម និងទីលំនៅបច្ចុប្បន្ននៅភូមិចុងបង្គោល ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] **ហេវឿន** (រស់) ម្តាយឈ្មោះ [redacted] សុភ័ក្រ (រស់) ប្តីឈ្មោះ [redacted] **រក្សា** (រស់) កូនគ្មាន កម្រិតវប្បធម៌ថ្នាក់ទី១២ ជានីតិជន ទោសពីមុនគ្មាន។

-ជាប់ចោទពីបទៈ **ឆបោក** ប្រព្រឹត្តនៅភូមិចុងបង្គោល ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២ តាមបញ្ញត្តិ**មាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ**។

-ដើមបណ្តឹងរដ្ឋប្បវេណីៈ

ឈ្មោះ [redacted] សិទ្ធី ភេទប្រុស អាយុ ៣៨ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅភូមិទី៣ សង្កាត់កំពង់ធំ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ។



Scanned with CamScanner

ឈ្មោះ [redacted] ស្រីគុណ ភេទស្រី អាយុ ២៨ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅភូមិចុងបង្គោល ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល។

ឈ្មោះ [redacted] ផល្លា ភេទស្រី អាយុ ២៣ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅភូមិមនោរម្យ ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល។

ឈ្មោះ [redacted] ស៊ាវអេង ភេទស្រី អាយុ ២៩ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅភូមិសំបួរ ឃុំព្រៃផ្តៅ ស្រុកព្រៃកប្បាស ខេត្តតាកែវ។

ឈ្មោះ [redacted] តាប៉ាវុធ ភេទប្រុស កើតឆ្នាំ១៩៨៧ ជនជាតិខ្មែរ មានទីលំនៅភូមិថ្នល់កែង ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តបន្ទាយមានជ័យ។

## ដំណាលរឿងហេតុមានដូចតទៅ ៖

កាលពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២ ស្ថិតនៅភូមិចុងបង្គោល ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល ជនត្រូវចោទឈ្មោះ [redacted] ស្រីនិត ភេទស្រី អាយុ ២២ឆ្នាំ ជាអ្នកវេលុយតាមទូរម៉ាន់នី ដែលមានថៅកែឈ្មោះ [redacted] ហារីសុន ភេទប្រុស អាយុ ៥០ឆ្នាំ ជនជាតិខ្មែរ បានប្រើតួនាទីខ្លួនជាបុគ្គលិក បានធ្វើជាឆាតទៅជនរងគ្រោះឈ្មោះ [redacted] សិទ្ធី ភេទប្រុស អាយុ ៣៥ឆ្នាំ មុខរបរ អាជីវករ ឈ្មោះ [redacted] ស្រីគុណ ភេទស្រី អាយុ ២៨ឆ្នាំ មុខរបរ អាជីវករ ឈ្មោះ [redacted] ផល្លា ភេទស្រី អាយុ ២៣ឆ្នាំ មុខរបរ អាជីវករ និងឈ្មោះ [redacted] ស៊ាវអេង ភេទស្រី អាយុ ២៩ឆ្នាំ មុខរបរ អាជីវករ ម្តងម្នាក់ៗដើម្បីសុំដូរលុយពីជនរងគ្រោះ យកទៅធ្វើការប្តូរលុយឲ្យអតិថិជនផ្សេងទៀតដើម្បីយកចំណេញភាគលាភ។ ដោយការជឿទុកចិត្ត និងចង់បានចំណេញភាគលាភដែរនោះ ជនរងគ្រោះឈ្មោះ [redacted] សិទ្ធី បានវេលុយចំនួន ៨២,១៥០០,០០០រៀល ឈ្មោះ [redacted] ស្រីគុណ បានវេលុយចំនួន ១៨,០០០,០០០រៀល និងវេលុយចំនួន ៣២០$ ឈ្មោះ [redacted] ផល្លា បានវេលុយចំនួន ២,៥០០ដុល្លាអាមេរិក និងឈ្មោះ [redacted] ស៊ាវអេង បានវេលុយចំនួន ៤០,២៦៨,២០០រៀល ទៅឲ្យជនត្រូវចោទឈ្មោះ [redacted] ស្រីនិត តាមរយៈកុងគណនេយ្យធនាគារផ្សេងៗគ្នា ដោយសង្ឃឹមថា ជនត្រូវចោទនឹងសងប្រាក់ដើម និងភាគលាភមកវិញ។ ប៉ុន្តែបន្ទាប់ពីជនត្រូវចោទទទួលបានលុយពីជនរងគ្រោះមកហើយ ជនត្រូវចោទបានគេចវេស មិនសងលុយដែលដូរនោះទៅឲ្យម្ចាស់បំណុលវិញទេ ដោយយកលេសឆ្លើយថាខ្វះលុយ និងប្រព័ន្ធអ៊ីនធ័រណេតមានបញ្ហា ទើបជនរងគ្រោះខាងលើដាក់ពាក្យបណ្តឹងទៅសមត្ថកិច្ចនគរបាល នៃអធិការដ្ឋាននគរបាលស្រុកអង្គស្នួល ធ្វើការចាប់ខ្លួនជនត្រូវចោទនាំយកទៅសាកសួរ និងចាប់យកវត្ថុតាង ទូរស័ព្ទដៃចំនួន ១គ្រឿង(ជារបស់ជនត្រូវចោទ) រួចក៏សាងសំណុំរឿងបញ្ជូនជនត្រូវចោទ និងវត្ថុតាង មកអយ្យការអមសាលាដំបូងខេត្តកណ្តាល ដើម្បីចាត់ការតាមច្បាប់។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានពិនិត្យឯកសារនានានៅក្នុងសំណុំរឿង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យ និងពិចារណាតាមផ្លូវច្បាប់រួចរាល់ហើយ



Scanned with CamScanner

## សាលាដំបូងខេត្តកណ្ដាល

## យល់ឃើញថា :

១-យោងតាមការពិនិត្យឯកសារ ព្រមទាំងភស្តុតាងនានាដែលមានក្នុងសំណុំរឿងឃើញថា អង្គហេតុដែលតំណាងអយ្យការធ្វើការចោទប្រកាន់មកលើជនជាប់ចោទឈ្មោះ [redacted] ស្រីនិត ភេទស្រី អាយុ ២២ឆ្នាំ ពីបទៈ ឆបោក ប្រព្រឹត្តនៅភូមិចុងបង្គោល ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្ដាល កាលពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២ គប្បីតុលាការធ្វើការពិចារណាអំពីអង្គហេតុដែលចោទប្រកាន់។

២-ជនជាប់ចោទឈ្មោះ [redacted] ស្រីនិត ភេទស្រី អាយុ ២២ឆ្នាំ ជានីតិជន ហើយជនជាប់ចោទមានស្មារតី និងសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនចំពោះមុខច្បាប់ ពោលគឺជនជាប់ចោទមិនមានសញ្ញាណាណាមួយដែលបង្ហាញថាជនជាប់ចោទមានសតិវិបល្លាសស្មារតីក្នុងពេលប្រព្រឹត្តបទល្មើសនោះឡើយ ដែលជាហេតុមិននាំឲ្យមានការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួនទេ។

៣-អំពើរបស់ជនជាប់ចោទៈ

៣.១ យោងតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ស្រីនិត ភេទស្រី អាយុ ២២ឆ្នាំ នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ថានៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២ ម៉ោង០៧ និង ១០នាទី ខ្លួនកំពុងនៅផ្ទះសម្រាកស្រាប់តែពេលនោះឈ្មោះបងនាងទូរស័ព្ទមកខ្លួនថា ទិញដុល្លារចំនួន៣,០០០$ ហើយខ្លួនប្រាប់គាត់វិញថា ខ្លួនមានលុយក្នុងកុងតែចំនួន៥០០$ទេ តែចាំខ្លួនសួរគ្នាខ្លួនសិន ហើយខ្លួនបានទូរស័ព្ទទៅឈ្មោះ [redacted] ផល្លា ភេទស្រី ខ្លួនសួរថាមានលុយក្នុងកុងចំនួន២,៥០០$អត់ គេទិញដុល្លារកាត់ព្រឹក ខ្លួនខ្វះលុយចំនួន២,៥០០$ ឱ្យខ្លួនខ្ចីលុយនឹងសិនមក នៅពេលនោះឈ្មោះ [redacted] ផល្លា ក៏បានបាញ់លុយតាមទូរ៉ូម៉ាន់នីឱ្យមកខ្លួនចំនួន២,៥០០$ ហើយខ្លួនក៏បានបាញ់លុយតទៅឱ្យគេចំនួន៣,០០០$ ដែលភ្ញៀវបានទិញដុល្លារពីខ្លួន។ ចំពោះលុយចំនួន ២,៥០០$ ដែលខ្លួនខ្ចីពីឈ្មោះ ផល្លា គឺរូបខ្លួនមិនទាន់បានបាញ់ឱ្យឈ្មោះ ផល្ល វិញទេ។ នៅថ្ងៃខែឆ្នាំដដែល ម៉ោង០៨ និង ៥០នាទី មានភ្ញៀវម្នាក់បានទាក់ទងមកខ្លួនតាមតេលេក្រាមបានសួរខ្លួនថា មានលុយខ្មែរអត់ ហើយខ្លួនបានសួរទៅវិញថា បងរកលុយខ្មែរប៉ុន្មាន ហើយភ្ញៀវឆ្លើយថា រកលុយខ្មែរចំនួន ២៥,០០០$ ហើយខ្លួនតបថា ខ្លួនមានតែចំនួន៥,០០០$ទេ ចាំបន្តិចខ្លួនឆាតសួរម៉ូយរបស់ខ្លួនសិន ហើយខ្លួនបានចូលមើលក្នុងគ្រុបឃើញបងឈ្មោះ [redacted] សិទ្ធី មានខ្មែរស្លាបនារីងចំនួន២០,០០០$ ដាក់ហាងឆេង៤១០៧.៥ ហើយ ខ្លួនបានឆាតទៅឈ្មោះ [redacted] សិទ្ធី ថាអស់លុយខ្មែរនៅបង ហើយគាត់ឆ្លើយប្រាប់ថា នៅបង ហើយខ្លួនបានប្រាប់ទៅ គាត់ថា យកចំនួន២០,០០០$ ហើយខ្លួនបានដាក់លេខកុងស្លាបនារបស់ខ្លួនឱ្យទៅគាត់ នៅពេលនោះបង [redacted] សិទ្ធី បានដាក់លុយខ្មែរចំនួន៨២,១៥០,០០០រៀល ចូលកុងស្លាបនារបស់ខ្លួន ហើយខ្លួនទៅដកលុយពីកុងស្លាបនាហើយ យកទៅដាក់ក្នុងទូរ៉ូម៉ាន់នី ហើយខ្លួនបានបាញ់លុយឱ្យគេដែលដូរចំនួន២៥,០០០$ បានប្រហែល១០នាទី បានគេទៅភ្ញៀវដែលឆាតមកដូរលុយហើយសួរគាត់ថា ម៉េចហើយលុយដុល្លារអត់ឃើញដាក់ឱ្យខ្លួន ឥឡូវគេចាំខ្លួនដែរ ហើយភ្ញៀវឆ្លើយតបមកវិញថា អត់ដឹងទេ ប្លុកហើយបិទទូរស័ព្ទចោលតែម្ដង ទាក់ទងលែងបានហើយលុបទាំងសារផ្ញើលុយថែមទៀត។ ហើយបង [redacted] សិទ្ធី បានទូរស័ព្ទមកខ្លួនម៉េចហើយ អត់ឃើញដាក់លុយឱ្យ ហើយខ្លួនឆ្លើយថា ចាំបន្តិចនាំយកលុយទៅដាក់ក្រៅឱ្យ ហើយខ្លួនចាំខាងគេដាក់លុយឱ្យដែរ។ ចំពោះលុយចំនួន៨២,១៥០,០០០រៀល ដែលខ្លួនបានឱ្យឈ្មោះ [redacted] សិទ្ធី ដាក់តាមស្លាបនាឱ្យខ្លួននោះ ខ្លួនមិនទាន់



Scanned with CamScanner

បានផ្ញើឱ្យគាត់វិញទេ។ នៅថ្ងៃខែឆ្នាំដដែល ម៉ោង១០ និង ១៩នាទី ខ្លួនបានឆាតជាសំឡេងតាមឆាតទៅឈ្មោះ ឯក ស្រីគុណា ភេទស្រី អាយុ ២៨ឆ្នាំ ជាអ្នកដាក់ ដកវីង ហើយខ្លួនបានឆាតថា បងខ្លួនខ្ចីលុយចំនួន២០$ ABA ហើយគាត់បានបាញ់ឱ្យ។ ដល់ម៉ោង១០ និង ២៤នាទី ខ្លួនបានឆាតសរសេរជាអក្សរ បងខ្លួនសុំខ្ចីលុយចំនួន ៣០០$ទៀតតាមABA ពេលនោះបងស្រីគុណា បានបាញ់លុយ ចំនួន៣០០$ ឱ្យមកខ្លួនតាមវីងឱ្យខ្លួន។ ដល់ម៉ោង១២ និង ២៥នាទី ខ្លួនបានឆាតជាសរសេរជាអក្សរថា បងឱ្យខ្លួនខ្ចីលុយ ចំនួន១៨លាន មួយភ្លែតមក ហើយបងស្រីគុណា បានសួរខ្លួនថាចូលធ្វើការហើយមែន ខ្លួនបានឆ្លើយតបទៅវិញថា នៅទេបង ហើយគាត់សួរខ្លួនទៀតថា យកលុយធ្វើអីចុះ ហើយខ្លួនប្រាប់គាត់វិញថា ខ្ចីលុយតែមួយភ្លែតទេបង ហើយគាត់បានសុំលេខកុងខ្មែរវីងពីខ្លួន ពេលនោះខ្លួនបានផ្ញើលេខកុងឱ្យទៅ ហើយគាត់បានបាញ់លុយឱ្យខ្លួនចំនួន១០លានរៀល និងតាមកុងធនាគារស្ថាបនាចំនួន៨លានរៀល ទៀត សរុបចំនួន១៨លានរៀល។ ក្រោយមកបានរយៈពេល ១០នាទី បងស្រីគុណា បានឆាតមកសួរខ្លួនថា ម៉េចហើយលុយបង មានបញ្ហាអីមែន ហើយខ្លួនតបទៅគាត់វិញថា អត់មានទេ ពេលនោះគាត់បានតេតាមលេខទូរស័ព្ទមកសួរខ្លួនទៀតថា មានរឿងអីមែនប្រាប់បងត្រង់មក ឃើញគេផុសរូបឯងក្នុងគ្រុបដូរលុយ ហើយខ្លួនបានតបថាមានណាបង គាត់ប្រាប់ថាឯងចូលមើលៗ មើលហើយខ្លួនឆ្លើយ ប្រាប់ទៅវិញថា អត់មានទេ ហើយបានបិទទូរស័ព្ទ។ ស្រាប់តែពេលនោះបងស្រីគុណា បានជិះម៉ូតូមកដល់ផ្ទះខ្លួន ហើយបានសួរខ្លួនថា ម៉េចហើយលុយបងគិតម៉េច ហើយខ្លួនបានឆ្លើយថា ដូចបងឯងឃើញអញ្ចឹង ហើយលែងមាត់ គ្រប់គ្នាហើយនាំគ្នាមកអធិការដ្ឋាននគរបាលស្រុក ដើម្បីរកដំណោះស្រាយបន្តតាមនីតិវិធីច្បាប់។ នៅថ្ងៃទី ០១ ខែធ្នូ ឆ្នាំ២០២២ ម៉ោង១៣ និង ០៤នាទី ខ្លួនបានមើលក្នុងគ្រុបដូរលុយ ហើយនៅពេលបើកឃើញនោះ ឈ្មោះ អ៊ា សាវអេង ផុលលុយខ្មែរចង់ដូរយកដុល្លារ។ ចំនួន៤០,២៦៨,២០០រៀល ហើយខ្លួនបានទាក់ទងទៅគាត់ ហើយខ្លួនបានដាក់លេងកុងអេស៊ីលីដាឱ្យទៅគាត់ ហើយគាត់បានដាក់លុយខ្មែរចំនួន៤០,២៦៨,២០០ រៀល តាមរយៈធនាគារអេស៊ីលីដាឱ្យរូបខ្លួន ហើយខ្លួនមិនបានដាក់លុយដល្លារចំនួន៩,៨០០$គត់ ឱ្យទៅឈ្មោះ អ៊ា សាវអេង វិញ ទេ។

ចំណែកឯនៅតំណាក់កាលអយ្យការបានឆ្លើយថា ខ្លួនទទួលស្គាល់ ចម្លើយនៅសមត្ថកិច្ចទុកជាបានការដដែល ដោយសុំកែនូវចំណុចមួយចំនួន។ ខ្លួនសុំកែត្រង់ថា កន្លែងដែលខ្លួនឆ្លើយនៅសមត្ថកិច្ចថា ទីតាំងដែលបើកវេរលុយទ្រូម៉ាន់នីនោះជាកន្លែងរបស់ខ្លួនបើកផ្ទាល់ តែកន្លែងបើកវេរលុយទ្រូម៉ាន់នីនោះជាកន្លែងថៅកែខ្លួន ឈ្មោះ [redacted] ហារីសុន ភេទប្រុស អាយុ៥០ឆ្នាំ ជនជាតិខ្មែរ រស់នៅភូមិចុងបង្គោល ស្រុកអង្គស្នួល ខេត្តកណ្តាល គាត់ជួលទីតាំងនោះឱ្យខ្លួនធ្វើការវេរលុយនោះ ដោយឈ្មោះ [redacted] ហារីសុន ឱ្យជាប្រាក់ខែមកខ្លួនក្នុង ១ខែ ចំនួន២៥០$។ ខ្លួនសូមបញ្ជាក់ថា ចំពោះការបើកមុខរបរវេរលុយ គឺពួកខ្លួនមានជាគ្រុបតេលេក្រាម ឈ្មោះ "សហគមន៍ទិញលក់លុយខ្មែរដុល្លារ"។ ខ្លួនធ្វើការនៅទីនោះជិត ៣ឆ្នាំ មកហើយ ពេលដែលត្រូវការលុយមកដាក់បង្វិលនៅទីតាំងដែលខ្លួនបើក គឺថៅកែឈ្មោះ [redacted] ហារីសុន គាត់ តែងតែឱ្យខ្លួនធ្វើការដោះដូរលុយពីអ្នកនៅគ្រុបនោះសឹងតែរាល់ថ្ងៃ។ លុយដែលខ្លួនដោះដូរជាមួយអ្នកនៅក្នុងគ្រុប ហើយពុំបានវេរឱ្យទៅជនរងគ្រោះទាំង៤នាក់ វិញ គឺសរុបទឹកប្រាក់ទាំងអស់ចំនួន៣២,៦២០ដុល្លារអាមេរិក និងលុយខ្មែរចំនួន១៨លានរៀល ពីមនុស្សចំនួន៤នាក់ មានឈ្មោះ [redacted] ផល្លា ភេទស្រី ឈ្មោះ [redacted] សិទ្ធី ភេទប្រុស ឈ្មោះ [redacted] ស្រីគុណា ភេទស្រី និងឈ្មោះ [redacted] សាវអេង ភេទស្រី លុយនោះខ្លួនយកទៅទូទាត់ជាមួយថៅកែ។ ចំណែកឯលុយដែលក្រៅពី ៤



Scanned with CamScanner

លានរៀល ១០ប៉ុង នៅសល់ប៉ុន្មានខ្លួនដកលុយថៅកែឈ្មោះ [redacted] ហារីសុន ដោះស្រាយជីវភាព ហើយខ្លួនដោះដូរលុយគេនៅក្នុងគ្រុបខាងលើ ដើម្បីបង្វិលឱ្យថៅកែវិញ ហើយពេលដែលខ្លួនគ្មានលុយដោះដូរឱ្យគេនៅក្នុងគ្រុបចំនួន៤នាក់ ខាងលើវិញ ពួកគាត់ក៏បានប្ដឹងខ្លួនឱ្យសមត្ថកិច្ចឃាត់ខ្លួនតែម្ដង។ ខ្លួនទទួលស្គាល់ពិតជាបានដោះដូរលុយជាមួយអ្នកទាំង៤នាក់ ខាងលើពិតមែន ហើយខ្លួនពុំបានវេរឱ្យទៅគេវិញទេ។ កន្លងមក ខ្លួនធ្លាប់ដោះដូរលុយជាមួយជនរងគ្រោះទាំង៤នាក់ ខាងលើនេះ រយៈពេលផ្សេងគ្នា ដោយខ្លួន និងឈ្មោះ [redacted] ស្រីគុណ ដោះដូរលុយគ្នាតាំងពីឆ្នាំ២០២០ តែខ្លួនពុំចាំខែនោះទេ បន្ទាប់មកខ្លួនដោះដូរប្រាក់ជាមួយឈ្មោះ [redacted] សិទ្ធី តាំងពីឆ្នាំ២០២១ តែពុំចាំខែនោះទេ ក្រោយមកខ្លួនបាន ដោះដូរលុយជាមួយឈ្មោះ [redacted] ផល្លា បានរយៈពេល៣ខែ មកហើយ គឺនៅខែកញ្ញា ឆ្នាំ២០២២ ហើយពួកខ្លួនដោះដូរលុយគ្នារហូតតែពុំដែលមានបញ្ហានោះទេ ចំណែកឯឈ្មោះ [redacted] ស៊ាវអេង គឺទើបតែដោះដូរលុយគ្នានៅថ្ងៃ ទី០១ ខែធ្នូ ឆ្នាំ២០២២។ ដោយនៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២ អ្នកទាំង៤នាក់ខាងលើ បានវេរលុយឱ្យខ្លួនដោយឈ្មោះ [redacted] ផល្លា វេរលុយឱ្យខ្លួនចំនួន ២,៥០០$ ឈ្មោះ [redacted] សិទ្ធី វេរលុយឱ្យខ្លួនចំនួន ៨២,១៥០,០០០រៀល ស្មើនឹង២០,០០០$ ឈ្មោះ [redacted] ស្រីគុណ វេរលុយឱ្យខ្លួនចំនួន១៨លានរៀល និង៣២០$ និងឈ្មោះ [redacted] ស៊ាវអេង វេរលុយឱ្យខ្លួនបើគិតជាដុល្លារទាំងអស់ចំនួន៩,៨០០$ តែគាត់វេរលុយខ្មែរឱ្យខ្លួននោះទេ តែខ្លួនពុំចាំថាប៉ុន្មាននោះទេ។ ពេលដែលខ្លួន និងអ្នកទាំង៤នាក់ខាងលើ ព្រមព្រៀងគ្នាដូរលុយ គឺខ្លួនត្រូវវេរលុយឱ្យទៅអ្នកទាំង៤នាក់វិញភ្លាមៗ "បើខ្លួនគ្មានលុយខ្មែរ គឺខ្លួនឱ្យគេវេរលុយខ្មែរឱ្យខ្លួន ហើយខ្លួនវេរលុយដុល្លារឱ្យទៅគេវិញ"។ ពេលដែលខ្លួនទទួលលុយពីអ្នកទាំង៤នាក់ខាងលើហើយ ម្ចាស់លុយបានទំនាក់ទំនងមកកាន់ខ្លួនដើម្បីឱ្យខ្លួនវេរលុយឱ្យគេវិញ តែខ្លួនបានរកលេសដោះសារថាម៉ាស៊ីនគាំង ហើយពុំបានវេរលុយឱ្យទៅអ្នកទាំង៤នាក់នោះទេ។ បុរសដែលខ្លួនវេរលុយឱ្យ គឺខ្លួនពុំចាំឈ្មោះនោះទេ លេខទូរស័ព្ទក៏ខ្លួនពុំចាំ ព្រោះខ្លួនបានវេរលុយ ទៅឱ្យបុរសម្នាក់នោះក្នុងអំឡុងខែតុលា ឆ្នាំ២០២២ ទំនាក់ទំនងព្រមព្រៀងវេរលុយតាមរយៈតេលេក្រាម ដោយបុរសនោះបានសរសេរជាសារមកកាន់ខ្លួនថា ជួយវេរលុយឱ្យតាមលេខទូរស័ព្ទដែលទំនាក់ទំនងក្នុងតេលេក្រាម ទឹកប្រាក់ចំនួន៤លានរៀល និងចំនួន១០ប៉ុង សរុបទឹកប្រាក់ចំនួន៤០លានរៀល ដោយគាត់ត្រូវផ្ទេរឱ្យខ្លួនវិញតាមរយៈ ABA ដោយកន្លងមកពុំដែលមានបញ្ហា ទើបតែវេរលុយឱ្យគាត់ថ្ងៃចុងក្រោយនោះ ស្រាប់តែគាត់ប្លុកលេខខ្លួនចោលតែម្ដង ហើយពុំវេរលុយឱ្យខ្លួននោះទេ។ គ្រុបសមាគមន៍នោះដែរ គឺថៅកែខ្លួនជាអ្នកអេតខ្លួនចូល ហើយខ្លួនពុំសូវស្គាល់អ្នកនៅក្នុងគ្រុបនោះទេ គ្រាន់តែរកស៊ីជាមួយគ្នាធម្មតា ពុំដែលមានបញ្ហានោះទេ ហើយបុរសដែលខ្លួនវេរលុយឱ្យនោះ គឺជាម៉ូយធ្លាប់វេរលុយឱ្យគាត់រាល់ដង ដោយគាត់វេរលុយឱ្យវិញតាមរយៈកុងABA។ ខ្លួនសូមបញ្ជាក់ថា ហាងឆេងដែលខ្លួនដោះដូរលុយជាមួយជនរងគ្រោះទាំង៤នាក់ខាងលើ គឺខ្លួនទិញតម្លៃហាងឆេងទូទៅនៅក្នុងគ្រុបតេលេក្រាម ព្រោះក្នុងគ្រុបតេលេក្រាម "សមាគមន៍ទិញលក់លុយខ្មែរដុល្លារ" សមាជិកតែងតែទម្លាក់តម្លៃហាងឆេងដូរលុយជារៀងរាល់ថ្ងៃ ដោយហាងឆេងនៅក្នុងគ្រុបខ្ពស់ជាងនៅហាងឆេងនៅធនាគារដោយ១ដុល្លារអាមេរិក ស្មើនឹងអត្រាប្រាក់៤១០៧.៥រៀល។ ពេលដែលខ្លួនដឹងថាបុរសដែលខ្លួនវេរឱ្យបោកខ្លួន គឺខ្លួនពុំបានប្រាប់ថៅកែទេ ឬក៏ប្ដឹងទៅសមត្ថកិច្ចទេ ដោយសារខ្លួនខ្លាចមានបញ្ហា សូម្បីតែគ្រួសារក៏ខ្លួនពុំបានប្រាប់ដែរ។ លុយដែលខ្លួនវេរឱ្យទៅបុរសខាងលើ គឺខ្លួនវេរតាមរយៈម៉ាស៊ីនទ្រូម៉ាន់នី ហើយបុរសនោះត្រូវវេរឱ្យ ខ្លួនវិញតាមរយៈកុងABA វេរជាកុងលុយខ្មែរ ដោយកុងABA ខ្លួនមានគណនីលេខ០០២៧២១១៧៩ (HORN_RREYNITH) ហើយកុងABAរបស់

បុរសម្នាក់នោះ ខ្លួនពុំចាំនោះទេ ទាល់តែខ្លួនឆែកក្នុងទូរស័ព្ទសិន ចំណែកឯម៉ាស៊ីនទ្រូម៉ាន់នី គឺរក្សាទុកទិន្នន័យបានរយៈពេលតែ១៤ថ្ងៃនោះទេ ចំណែកក្រដាសទិន្នន័យដែល ចេញពីម៉ាស៊ីនប្រូម៉ាន់នី គឺរយៈពេល១ខែ គឺកន្លែងខ្លួនប្រមូលចោលម្តង។

ដោយឡែកនៅដំណាក់កាលចៅក្រមស៊ើបសួរ ក៏ដូចជានាពេលសវនាការ បានឆ្លើយប្រហាក់ប្រហែលគ្នាថា ខ្លួនសូមបដិសេធចម្លើយដែលខ្លួនឆ្លើយនៅអធិការដ្ឋាននគរបាលស្រុកអង្គស្នួល កាលពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២ ចោលដោយសារថៅកែឈ្មោះ [redacted] ហារីសុន ជាអ្នកបង្គាប់ឱ្យឆ្លើយ។ ខ្លួនសូមរក្សាចម្លើយដែលខ្លួនបាន ឆ្លើយនៅអយ្យការ កាលពីថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២២ ទុកជាបានការដដែល។ ខ្លួនទទួលស្គាល់ថាពិតជាបានទទួលប្រាក់ពីឈ្មោះ [redacted] សិទ្ធី ចំនួន៨២,១៥០,០០០រៀល ពីឈ្មោះ [redacted] ស្រីគុណ ចំនួន១៨លានរៀល និង៣២០$ ពីឈ្មោះ [redacted] ផល្លា ចំនួន២,៥០០$ ពីឈ្មោះ [redacted] ស៊ាវអេង ចំនួន៤០,២៦៨,២០០រៀល ពិតប្រាកដមែន។ ឈ្មោះ [redacted] សិទ្ធី ឈ្មោះ [redacted] ស្រីគុណ ឈ្មោះ [redacted] ផល្លា នេះធ្លាប់វេរលុយឱ្យខ្លួនជាច្រើនលើកមកហើយ ពុំដែលមានបញ្ហាអ្វីទេ។ ចំពោះឈ្មោះ [redacted] ស៊ាវអេង ទើបតែវេរលុយជាលើកទី១ទេ។ ក្រោយពីទទួលលុយហើយ ខ្លួនបានវេរលុយនេះទៅឱ្យថៅកែឈ្មោះ [redacted] ហារីសុន រួចរាល់អស់ហើយ។ ខ្លួនសូមបញ្ជាក់ថាលុយដែលវេរមកតាមរយៈខ្លួនតែម្នាក់ឯងទេ ហើយខ្លួនវេរលុយទៅឱ្យថៅកែតែមួយឈ្មោះ គឺឈ្មោះ [redacted] ហារីសុន ទាំងអស់។ របាយការណ៍ដែលខ្លួនទទួលប្រាក់ពីអ្នកទាំងបួន និងវេរប្រាក់ទៅឱ្យថៅកែឈ្មោះ [redacted] ហារីសុន គឺនៅទូរស័ព្ទ ១៣ប្រូម៉ែក ដែលបានដកហូតពីរូបខ្លួន។ ខ្លួនសូមបញ្ជាក់ថា នៅពេលប្រគល់ប្រាក់ទៅម្ចាស់ដើមវិញ គឺថៅកែគាត់មានភារៈកិច្ចផ្ទេរសាច់ប្រាក់ចូលកុងខ្លួន ហើយខ្លួនវេរសាច់ប្រាក់ទៅឱ្យម្ចាស់ដើម។ ប៉ុន្តែពេលនេះថៅកែអត់បានវេរលុយចូលកុងខ្លួន នេះជាមូលហេតុខ្លួនអត់លុយវេរបន្តទៅឱ្យម្ចាស់លុយទាំង ៤នាក់។ មូលហេតុដែលដាក់ឈ្មោះខ្លួន ជាម្ចាស់ទ្រូម៉ាន់នី គឺឈ្មោះ [redacted] ហារីសុន នេះគាត់មានឈ្មោះបើកវីង ហើយគាត់មិនអាចបើកកន្លែងវេរលុយឈ្មោះផ្សេងបានទេ ហើយឱ្យខ្លួនចេញមុខជំនួស។ អ្នកធ្វើការជាមួយថៅកែនេះ គឺឈ្មោះ [redacted] សូរីណេត ក៏គាត់(ថៅកែ)ឱ្យឈរឈ្មោះបើកទ្រូម៉ាន់នីនេះដែរ។ មានន័យថា ថៅកែខ្លួនបើកទ្រូម៉ាន់នី និងឈ្មោះ [redacted] សូរីណេត បើកទីតាំងខុសគ្នា។ ខ្លួនធ្វើការជាមួយគាត់អស់រយៈពេលជិត ៣ឆ្នាំមក មិនដែលមានបញ្ហាអ្វីកើតឡើងទេ ទើបតែមួយដងនេះទេ ខ្លួនទទួលប្រាក់ទាំងអស់នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២ គ្រាន់តែខុសម៉ោង ហើយក៏វេរទៅឱ្យថៅកែវិញទាំងអស់តាមពេលម៉ោង តែខ្លួនបានទទួលបានពីភ្ញៀវ។ ខ្លួនត្រូវថៅកែនេះដោះយកខ្សែមាសមួយខ្សែ ចិញ្ចៀនចំនួន ២វង់។ ថៅកែខ្លួនគាត់រកស៊ីតែរបបវេរលុយទៅមកតែអញ្ចឹង។ នៅពេលខ្លួនវេរលុយទៅឱ្យថៅកែ គឺខ្លួនអត់ដឹងថាគាត់វេរលុយទៅឱ្យអ្នកណាទេ។ ជាធម្មតាពេលថៅកែទទួលការវេរប្រាក់ពីខ្លួន ហើយប្រហែលជាង១០នាទី គាត់វេរមកឱ្យខ្លួនវិញហើយ ខ្លួនវេរឱ្យម្ចាស់ដើមវិញ។ លុយដែលខ្លួនវេរឱ្យថៅកែ គឺវេរឱ្យឈ្មោះ [redacted] ហារីសុន លោតចេញឈ្មោះអ្នកទទួល ឈ្មោះ [redacted] ហារីសុន ទទួលទាំងអស់ យកទូរស័ព្ទខ្លួនមកទៅឃើញ។

៣.២ យោងតាមការបំភ្លឺរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សិទ្ធី ភេទប្រុស អាយុ ៣៨ឆ្នាំ នៅដំណាក់កាលអយ្យការ ដំណាក់កាលចៅក្រមស៊ើបសួរ ក៏ដូចជានាពេលសវនាការ បានឆ្លើយប្រហាក់ប្រហែលគ្នាថា ខ្លួនពិតជាបានបាញ់លុយជនជាប់ចោទពិតមែនចំនួន ៨២,១៥០,០០០រៀល ខ្លួនធ្លាប់ស្គាល់ឈ្មោះ ស្រីនិតតាមទូរស័ព្ទ ខ្លួនធ្លាប់បានប្រតិបត្តិការជាមួយ [redacted] ស្រីនិត ពីមុនមក ហើយការប្រតិបត្តិការគឺយកលុយខ្មែរទិញ



Scanned with CamScanner

ដុល្លារ យកដុល្លារដូរលុយខ្មែរ ហើយការប្រតិបត្តិការនេះគឺផ្ញើទៅ ផ្ញើមកភ្លាមៗ ដោយទាក់ទងតាមរយៈគ្រុបតេឡេក្រាមដែលមានឈ្មោះ "សមាគមន៍ទិញលក់លុយខ្មែរដុល្លារ" ដំបូងឡើយខ្លួនមិនទាន់ស្គាល់គ្រុបតេឡេក្រាមនោះទេ ទើបតែក្រោយមកឃើញគេដូរទៅដូរមក ខ្លួនក៏ដូរតាមគេដែរ ខ្លួនមិនធ្លាប់ដឹងថា [redacted] ស្រីនិត ធ្វើការឲ្យគេ ឬធ្វើខ្លួនឯងទេ គណនីដែលខ្លួនវេរឲ្យជូនឈ្មោះ [redacted] ស្រីនិត ផ្ទាល់ ជូនឈ្មោះ [redacted] ហារីសុន ខ្លួនធ្លាប់ធ្វើប្រតិបត្តិការជាមួយឈ្មោះ [redacted] ស្រីនិត ច្រើនលើកមកហើយ តាំងពីឆ្នាំ២០២១ ដោយការប្រតិបត្តិការមានតិចមានច្រើន។ ខ្លួនសូមឲ្យជនជាប់ចោទសងប្រាក់ដើមត្រឡប់មកវិញចំនួន ៨២,១៥០,០០០រៀល និងសូមទាមទារសំណងជំងឺចិត្ត និងខាតពេលវេលាចំនួន ៨០,០០០,០០០រៀល។

៣.៣ យោងតាមការបំភ្លឺរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីគុណ ភេទស្រី អាយុ ២៨ឆ្នាំ នៅដំណាក់កាលអយ្យការ ដំណាក់កាលចៅក្រមស៊ើបសួរ ក៏ដូចជានាពេលសវនាការ បានឆ្លើយប្រហាក់ប្រហែលគ្នាថា ខ្លួនធ្លាប់ធ្វើប្រតិបត្តិជាមួយ [redacted] ស្រីនិត ជាច្រើនដងមកហើយគឺមិនធ្លាប់មានបញ្ហាទេ ខ្លួនបានដឹងថា [redacted] ស្រីនិត ធ្វើការឲ្យ [redacted] ហារីសុន ដោយសារខ្លួន និង [redacted] ស្រីនិត ពីមុនធ្លាប់ធ្វើការជាមួយ [redacted] ហារីសុន ឈ្មោះ [redacted] ស្រីនិត បានឆាតមកខ្ចីលុយខ្លួនដំបូង ២០$ បាញ់តាមគុង ABA ក្រោយមកខ្ចី ៣០០$ ទៀតបាញ់តាម ABA ជាកុងគណនីរបស់ [redacted] ស្រីនិត លុះប្រហែលម៉ោង ១២ជាង ឈ្មោះ [redacted] ស្រីនិត បានឆាតមកខ្ចីលុយខ្លួន ១៨,០០០,០០០រៀល បន្ថែមទៀត ខ្លួនសួរថាយកលុយធ្វើអី ចូលធ្វើការវិញហើយមែន ហើយ [redacted] ស្រីនិត ឆ្លើយថា នៅទេ ថែមទាំងតឿនខ្លួនទៀតថា"ខ្ញុំខ្ចីតែមួយភ្លែតទេ"បន្ទាប់មកខ្លួនក៏បាញ់លុយឲ្យតាមកុងវីងចំនួន ១០,០០០,០០០រៀល និង ៨,០០០,០០០រៀល ទៀតបាញ់តាមកុងស្ថាបនារបស់ឈ្មោះ [redacted] ស្រីនិត។ក្រោយមកខ្លួនឃើញគេបង្ហោះរូប [redacted] ស្រីនិត នៅក្នុងគ្រុបថាជាជនឆបោក ខ្លួនក៏បានជិះមកម៉ូតូមកសួរ ហ៊ិន ស្រីនិត ផ្ទាល់ដល់ផ្ទះ សោម ហារីសុន ម៉ោងជិត១ ពេលទៅដល់ខ្លួនឃើញមានឈ្មោះ [redacted] ផល្លា ឈ្មោះ [redacted] ផល្លីន ឈ្មោះ [redacted] រក្សា ឈ្មោះ [redacted] ហារីសុន ឈ្មោះ [redacted] ស្រីនិត និងខ្លួន។ លុះប្រហែលជាម៉ោង៦ជាងល្ងាច ខ្លួនបានទៅអធិការ ហើយបានជួប ហ៊ិន ស្រីនិត ខ្លួនបានសួរថាលុយខ្លួន យកទៅណាតែ [redacted] ស្រីនិត មិនឆ្លើយអ្វីទាំងអស់។ [redacted] ស្រីនិត ត្រូវបានឈ្មោះ [redacted] ហារីសុន ជាអ្នកឃាត់ខ្លួន ហើយបានសួរថា មាននរណាដែល [redacted] ស្រីនិត ជំពាក់លុយទៀតទេ ហើយខ្លួនថាមិនមាន។ ម៉ោងជាង១ ខ្លួនបានជិះទៅផ្ទះ [redacted] ហារីសុន ហើយបានជួប [redacted] ស្រីនិត ហើយបានសួរថា លុយយកទៅណា ហើយមិនមាត់។ ពេលនោះ [redacted] ហារីសុន បានថា ផ្ទៀងផ្ទាត់បញ្ជីម្ដងទៀត គឺគាត់បានបាត់លុយដែរ។ ការងារវេរលុយនេះ គឺចៅកែខ្លួនឈ្មោះ [redacted] ហារីសុន បានបាញ់លុយទុកឲ្យកូនចៅពេលធ្វើការសម្រាប់លក់ចេញទិញចូលជាមួយភ្ញៀវ។ ក្រោយមក [redacted] ហារីសុន បានមកផ្ទះ [redacted] ស្រីនិត ដែរហើយប្រាប់ទៅ [redacted] សិទ្ធី ថាជាម្ចាស់ផ្ទះជួល។ លុះពេលល្ងាច [redacted] ហារីសុន បានជូនដើមបណ្ដឹងទៅដាក់ពាក្យបណ្ដឹងនៅអធិការដ្ឋាន។ ខ្លួនសូមទាមទារប្រាក់ដើម ១៨,០០០,០០០រៀល និង៣២០$ និងទាមទារសំណងជំងឺចិត្តចំនួន១០០០$។

៣.៤ យោងតាមការបំភ្លឺរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ផល្លា ភេទស្រី អាយុ ២៣ឆ្នាំ នៅដំណាក់កាលចៅក្រមស៊ើបសួរ ក៏ដូចជានាពេលសវនាការ បានបំភ្លឺប្រហាក់ប្រហែលគ្នាថា ខ្លួនស្គាល់ជាមួយឈ្មោះ ហ៊ិន ស្រីនិត រយៈពេល៥ ទៅ ៦ខែមកហើយ។ ខ្លួន និងស្រីនិត ជាអាជីវករអ្នករកស៊ីដូរលុយវេរលុយជាមួយគ្នា។ នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង៧ និង ២០នាទី ឈ្មោះ [redacted] ស្រីនិត បានឆាតមកតាមតេឡេ



Scanned with CamScanner

ក្រាម សុំឲ្យលុយខ្លួនចំនួន២៥០០ ដុល្លារអាមេរិក បន្ទាប់មកខ្លួនបានបាញ់ទឹកប្រាក់ទៅលេខកុង ២៤០១៣២២៣ ឈ្មោះ [redacted] ស្រីនិត។ ដោយសារតែខ្លួន និងស្រីនិត ជាអ្នករកស៊ីវេរលុយដូចគ្នាខ្លួនក៏ឲ្យខ្ចីប៉ុន្តែជាធម្មតាខ្ចីតែ១០នាទី ក៏ស្រីនិត បាញ់មកវិញ។ ប៉ុន្តែពេលនេះ ចាត់តាំងពីព្រឹករហូតមកដល់ម៉ោង១២ មិនឃើញវេរឲ្យខ្លួនក៏ដឹងតៗគ្នាថាអ្នកដែលបាញ់លុយឲ្យស្រីនិតនេះ គឺស្រីនិតពុំបានវេរលុយមកវិញទេ ទើបដឹងថាស្រីនិតនេះបោក ហើយនាំគ្នាពាក្យប្តឹងសមត្ថកិច្ចតែម្តង។ ខ្លួនសូមទាមទារប្រាក់ដើមចំនួន២៥០០ ដុល្លារអាមេរិក និងសូមទាមទារសំណងជំងឺចិត្ត ៥០០ដុល្លារអាមេរិក។

៣.៥ យោងតាមការបំភ្លឺរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ស៊ាវអេង** ភេទស្រី អាយុ ២៩ឆ្នាំ នៅដំណាក់កាលចៅក្រមស៊ើបសួរ ក៏ដូចជានាពេលសវនាការ បានឆ្លើយប្រហាក់ប្រហែលគ្នាថា ខ្លួនស្គាល់ឈ្មោះ [redacted] ស្រីនិត តាមតេឡេក្រាមរយៈពេល៥ខែមកហើយ។ ប៉ុន្តែមិនមានទំនាក់ទំនងរកស៊ីវេរលុយអ្វីជាមួយគ្នាទេ។ នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២ ម៉ោងមួយថ្ងៃត្រង់ឈ្មោះ [redacted] ស្រីនិត ទាក់ទងមកខ្លួនតាមប្រព័ន្ធតេឡេក្រាម ថាមានលុយដុល្លារ១០,០០០(មួយម៉ឺន)ដុល្លារអាមេរិក សម្រាប់លក់យកជាលុយខ្មែរពីខ្លួន។ ពេលខ្លួនប្រាប់គាត់ថាខ្លួនមានលុយខ្មែរអត់គ្រប់១០,០០០(មួយម៉ឺន)ដុល្លារអាមេរិកទេ ហើយស្រីនិតថាប៉ុណ្ណឹងក៏បានដែរ។ ខ្លួនវេរលុយទៅស្រីនិតតាមកុងអេស៊ីលីដារបស់គាត់ ចំនួន ៤០,២៦៨,២០០រៀល។ បន្ទាប់មកប្រហែល ១០នាទីខ្លួនទូរស័ព្ទទៅ គាត់ឆ្លើយថា អត់មានលុយវេរឲ្យទេ។

៣.៦ យោងតាមការបំភ្លឺរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **តាវ៉ាវុធ** ភេទប្រុស កើតឆ្នាំ១៩៨៧ នៅដំណាក់កាលចៅក្រមស៊ើបសួរ បានបំភ្លឺថា ខ្លួនសូមរក្សាការទាមទារដូចក្នុងបណ្តឹងចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២ ទុកជាបានការដដែល។ ខ្លួនស្គាល់ឈ្មោះ [redacted] ស្រីនិត នេះអស់រយៈពេលបីខែមកហើយ។ តែស្គាល់នេះតាមរយៈក្រុមវេរលុយតេឡេក្រាមឈ្មោះ [redacted] ស្រីនិត ដែលមានលេខទូរស័ព្ទ ០៨៦ ២៤ ៨៤ ២៧ ប្រព័ន្ធស្មាត។ ខ្លួនមានទំនាក់ទំនងជាច្រើនលើកមកហើយក្នុងការវេរលុយតាមរយៈលេខគណនីធនាគារស្ថាបនា ដែលមានលេខគណនី ០០១៥៥២៨៤ ឈ្មោះ HORN SREY NICH។ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២ ម៉ោង៦ និង ២៥នាទី ល្ងាចខ្លួនបានដាក់លុយខ្មែរតាមធនាគារស្ថាបនាចំនួន ២៥លានរៀល និងគណនីអេអុឹមខេ បាញ់ឆ្លងទៅគណនីឈ្មោះ [redacted] ស្រីនិត នេះចំនួន ១៦,១៣០,០០០រៀល នៅម៉ោង៦ និង ២៥នាទីល្ងាចដូចគ្នា។ ក្រោយពីដាក់បញ្ចូលលុយរួចហើយជាធម្មតារយៈពេលប្រហែលពី ១០នាទី ទៅ ៣០នាទី ក៏ឈ្មោះ ស្រីនិត បានវេរមកវិញជាធម្មតា។ ប៉ុន្តែពេលនោះឈ្មោះនេះ យកលេសថាម៉ាស៊ីនរបស់គាត់អត់មានអ៊ីនធើណេត បន្ទាប់មកគាត់ថាបិទបញ្ជីទៅបាត់លុយ។ លុះមកដល់ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង៩ និង ២៧នាទីព្រឹក ឈ្មោះ [redacted] ស្រីនិត បានវេរប្រាក់ដុល្លារចំនួន ៣០០០ដុល្លាអាមេរិក ចូលមកកុង ABA របស់ឈ្មោះ [redacted] តាវ៉ាវុធ។ នៅសល់ប្រាក់ ៧០០០ដុល្លារអាមេរិក គាត់មិនសងខ្លួនទេ ដោយយកលេសមានបញ្ហាទៅគូបរបស់គាត់លាក់ពន្ធលុយក្លែងក្លាយជាមួយអតិថិជន។ បន្តមកគាត់បានឆ្លើយប្រាប់ខ្លួនថាគាត់ចាញ់បោកគេដែរ អស់តាំងដើមចុងពីខ្លួនអស់ហើយ។ បន្ទាប់មកគាត់ថាបើចង់បានលុយមកជួបដោះស្រាយជាមួយគាត់ផ្ទាល់តែម្តង។

៣.៧ យោងតាមការបំភ្លឺរបស់សាក្សីឈ្មោះ [redacted] **សូរីណេត** ភេទស្រី អាយុ ២៩ឆ្នាំ នៅពេលសវនាការ បានឆ្លើយថា ខ្លួនបានទៅផ្ទះ [redacted] ហារីសុន ជាមួយគ្នា ប៉ុន្តែខ្លួនមិនដឹងថា [redacted] ហារីសុន និយាយអ្វីខ្លះនោះទេ។



Scanned with CamScanner

៣.៨ យោងតាមការបំភ្លឺរបស់សាក្សីឈ្មោះ [redacted] ស្រីនុច ភេទស្រី អាយុ ១៦ឆ្នាំ នៅពេលសវនាការ បានឆ្លើយថាខ្លួនមិនបានទៅផ្ទះ [redacted] ហារីសុន ទេ ខ្លួនដឹងតែរឿងវេរលុយឲ្យឈ្មោះ [redacted] ស្រីនិត។

៣.៩ យោងតាមការបំភ្លឺរបស់សាក្សីឈ្មោះ [redacted] ផល្លីន នៅពេលសវនាការ បានឆ្លើយថា ខ្លួនដឹងតែឈ្មោះ [redacted] ស្រីនិត បានខ្ចីលុយ ក្រៅពីនេះខ្លួនមិនដឹងរឿងអ្វីទៀតទេ។

*យោងតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ស្រីនិត** ភេទស្រី អាយុ ២២ឆ្នាំដែលបានឆ្លើយសារភាពនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ដំណាក់កាលអយ្យការ ដំណាក់កាលចៅក្រមស៊ើបសួរ រហូតដល់ដំណាក់កាលជំនុំជម្រះ ព្រមទាំងឯកសារផ្សេងៗទៀតដែលមាននៅក្នុងសំណុំរឿង និងយោងតាមការបំភ្លឺរបស់ដើមបណ្ដឹងឈ្មោះ [redacted] **សិទ្ធី** ភេទប្រុស អាយុ ៣៣ឆ្នាំ ឈ្មោះ [redacted] **ស្រីគុណា** ភេទស្រី អាយុ ២៨ឆ្នាំ ឈ្មោះ [redacted] **ផល្លា** ភេទស្រី អាយុ ២៣ឆ្នាំ ឈ្មោះ [redacted] **សាវអេង** ភេទស្រី អាយុ ២៩ឆ្នាំ និងឈ្មោះ [redacted] **តារ៉ាវុធ** ដែលបានឆ្លើយបំភ្លឺ នៅដំណាក់កាលចៅក្រមស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ និងឯកសារផ្សេងៗទៀតដែលមាននៅក្នុងសំណុំរឿង គឺពិតជាអាចឲ្យតុលាការជឿបានថា ជនជាប់ចោទឈ្មោះ [redacted] **ស្រីនិត** គឺពិតជាបានប្រព្រឹត្តអំពើ៖ ឆបោក ពិតប្រាកដមែន។*

៤-យោងតាមចំណុចទី៣ នៃផ្នែកសំអាងហេតុនៃសាលក្រមនេះឃើញថា បច្ច័យទាំងនេះគឺកើតចេញពីអំពើរបស់ជនជាប់ចោទដោយផ្ទាល់ ដែលតម្រូវឱ្យជនជាប់ចោទទទួលខុសត្រូវចំពោះអំពើល្មើសរបស់ខ្លួន។

៥-ធាតុអត្តនោម័តរបស់ជនជាប់ចោទឈ្មោះ [redacted] ស្រីនិត ភេទស្រី អាយុ ២២ឆ្នាំ គឺជានីតិជន ដែលមានស្មារតី មានការយល់ដឹង ព្រមទាំងមានវិចារណញ្ញាណគ្រប់គ្រាន់ដែលអាចវិនិច្ឆ័យបានថា អំពើដែលខ្លួនប្រព្រឹត្តគឺជាអំពើមិនល្អ ដែលសង្គមមិនទទួលស្គាល់ ហើយល្មើសទៅនឹងច្បាប់របស់ប្រទេសថែមទៀតផង ទោះបីជាដឹងយ៉ាងនេះក៏ដោយ ក៏ជនជាប់ចោទនៅតែមានឆន្ទៈ ក្នុងការប្រព្រឹត្តបទល្មើសដែលច្បាប់បានហាមឃាត់ដដែល ពោលគឺជនជាប់ចោទមានចេតនាយ៉ាងពិតប្រាកដ ក្នុងការប្រព្រឹត្តអំពើឆបោក ដោយឧបាយកលទុច្ចរិត ហើយជនជាប់ចោទបានដឹងយ៉ាងច្បាស់លាស់ថា ទង្វើដែលខ្លួនបានប្រព្រឹត្តនេះ គឺជាទង្វើខុសច្បាប់។

៦-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ស្រីនិត ភេទស្រី អាយុ ២២ឆ្នាំ ជាអំពើមួយដែលធ្វើឲ្យប៉ះពាល់សណ្ដាប់ធ្នាប់សាធារណៈ របៀបរៀបរយសង្គម ប៉ះពាល់ដល់សន្តិសុខសង្គម ជាពិសេសប៉ះពាល់ដល់ផលប្រយោជន៍ឯកជនរបស់អ្នកដទៃ ហើយជាអំពើមួយដែលច្បាប់បញ្ញត្តិចែងថា ជាអំពើ៖ **ឆបោក** បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិ**មាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ** គប្បីតុលាការសម្រេចធ្វើការប្រកាសទោសឲ្យជនជាប់ចោទទទួលខុសត្រូវតាមបញ្ញត្តិមាត្រាខាងលើ។

៧-មានធាតុផ្សំនៃបទល្មើស និងពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសទៅលើជនជាប់ចោទឈ្មោះ [redacted] **ស្រីនិត** ភេទស្រី អាយុ ២២ឆ្នាំ ពីបទ៖ **ឆបោក** ប្រព្រឹត្តនៅភូមិចុងបង្គោល ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្ដាល កាលពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិ**មាត្រា៣៧៧ មាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ**។

៨-មេធាវីការពារក្តីឲ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋាន៖ បន្ទាប់ពីបានធ្វើការពិភាក្សាដេញដោលរួចមក ឃើញថាកាលពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២ ពិតជាមានអង្គហេតុឆបោកប្រាក់កើតឡើង ប្រព្រឹត្តដោយឈ្មោះ ហ៊ិន ស្រីនិត ជាជនជាប់ចោទ ពិតប្រាកដមែន ដោយជនជាប់ចោទប្រើប្រាស់មធ្យោបាយក្នុងចេតនាទុច្ចរិត



Scanned with CamScanner

ធ្វើជាប្រកាសទិញលុយខ្មែរ ក្នុងឆាណែលតេឡេក្រាម (Telegram Channel) ចំនួន២០,០០០(ពីរម៉ឺន) ដុល្លារអាមេរិក បន្ទាប់មកក៏បានធ្វើការទំនាក់ទំនងជាមួយ កូនក្តីខ្លួន រហូតកូនក្តីខ្លួនឈ្មោះ [redacted] សិទ្ធី បានព្រមព្រៀងបាញ់លុយចំនួន៨២,១៥០,០០០ (ប៉ែតសិប ពីរលាន ដប់ប្រាំម៉ឺន) រៀល ឲ្យទៅជនជាប់ចោទ តាមគណនីស្តាបនាដែលជនជាប់ចោទទំលាក់ឲ្យតាមតេឡេក្រាមផ្ទាល់ខ្លួន ហើយជនជាប់ចោទត្រូវបាញ់លុយដុល្លារអាមេរិក ចំនួន ២០,០០០(ពីរម៉ឺន) ដុល្លារអាមេរិក ត្រឡប់មកឲ្យកូនក្តីខ្លួនវិញ។ ប៉ុន្តែនៅពេលដែលជនជាប់ចោទបានទទួលលុយពីកូនក្តីខ្លួនហើយ មិនធ្វើការបាញ់លុយដុល្លារសងមកកូនក្តីខ្លួនវិញទេ ថែមទាំងភូតកុហក់ រហូតដល់កូនក្តីខ្លួនដាក់ពាក្យបណ្តឹង និងធ្វើការឃាត់ខ្លួន។

យោងតាមចម្លើយរបស់ជនជាប់ចោទ នៅដំណាក់កាលមន្ត្រីនគបាលយុត្តិធម៌ជនជាប់ចោទបាន ឆ្លើយទទួលតែម្នាក់ឯង និងខំបំបិតថៅកែរបស់ខ្លួនឈ្មោះ [redacted] ហារីសុន ព្រោះជនជាប់ចោទឆ្លើយតាម ការបង្គាប់បញ្ជារបស់ថៅកែខ្លួន។

នៅដំណាក់កាលអយ្យការ និងដំណាក់កាលស៊ើបសួរ ក៏ដូចនៅពេលសវនាការនេះ គឺជនជាប់ចោទបានឆ្លើយសារភាព ទទួលស្គាល់ថាខ្លួនពិតជាបានប្រព្រឹត្តមែន។ ប៉ុន្តែលុយដែលទទួលបានពីកូនក្តីខ្លួន ក៏ដូចជាទទួលបានពីដើមបណ្តឹងផ្សេងៗទៀតនោះ គឺខ្លួនបានបាញ់ទៅឲ្យថៅកែរបស់ខ្លួនឈ្មោះ [redacted] ហារីសុន ទាំងអស់ ហើយថៅកែរបស់ខ្លួនពុំបានបាញ់លុយត្រឡប់មកឲ្យខ្លួនវិញទេ ហើយជនជាប់ចោទក៏ ពុំបានបាញ់លុយសងកូនក្តីខ្លួនដែរ។ ចំណុចនេះបញ្ជាក់ឲ្យឃើញថាជនជាប់ចោទពិតជាបានប្រព្រឹត្តហើយ ក៏មានការពាក់ព័ន្ធនឹងឈ្មោះ [redacted] ហារីសុន ជាអ្នកនៅពីក្រោយក្នុងរឿងនេះ។ ដូចនេះគួរតែតុលាការ កោះហៅឈ្មោះ [redacted] ហារីសុន មកបំភ្លឺទើបរកឃើញការពិត ព្រោះថា [redacted] ហារីសុន គឺតួអង្គសំខាន់ ដែលអាចឲ្យតុលាការរកឃើញនូវការពិត ប៉ុន្តែផ្ទុយទៅវិញតុលាការពុំបានធ្វើការកោះហៅមកធ្វើការសាកសួរទេចាប់តាំងពីដំណាក់កាលអយ្យការ និងដំណាក់កាលស៊ើបសួរហូតមកដល់ដំណាក់កាលជំនុំជម្រះ។

ចម្លើយរបស់ជនជាប់ចោទ គឺបានសារភាពគ្រប់ដំណាក់កាលនីតិវិធី ដែលចម្លើយនេះមានភាពស៊ីសង្វាក់ទៅនឹងចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ចម្លើយសាក្សី ជាមួយនឹងភស្តុតាង ដូចនេះអាចសន្និដ្ឋានបានថា ជនជាប់ចោទពិតជាបានធ្វើសកម្មភាពប្រព្រឹត្តបទល្មើស។ សកម្មភាពប្រព្រឹត្តរបស់ជនជាប់ចោទជា អំពើល្មើស ដែលមានធាតុផ្សំបទល្មើសគ្រប់គ្រាន់សម្រាប់ឲ្យតុលាការធ្វើការចោទប្រកាន់ និងផ្តន្ទាទោសបាន។ ក្នុងនាមខ្លួនជាមេធាវីតំណាង និងការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សិទ្ធី សូមសំណូមពរឲ្យតុលាការៈ

ក.ផ្តន្ទាទោសលើជនជាប់ចោទ ឈ្មោះ [redacted] ស្រីនិត ឲ្យបានធ្ងន់ធ្ងរ ដើម្បីឲ្យរាងចាល និងកុំឲ្យអ្នកផ្សេងយកគំរូតាម។

ខ.ស្នើសុំឲ្យតុលាការធ្វើការចោទប្រកាន់ និងផ្តន្ទាទោសទៅលើឈ្មោះ [redacted] ហារីសុន។

គ.ទាមទារប្រាក់ដើមចំនួន៨២,១៥០,០០០ (ប៉ែតសិបពីរលាន ដប់ប្រាំម៉ឺន)រៀល ឲ្យទៅកូនក្តីខ្លួនវិញ។

ឃ.ទាមទារសំណងខាតបង់ពេលវេលា ជំងឺចិត្ត និងចំណាយផ្សេងចំនួន ៨០,០០០,០០០(ប៉ែតសិបលាន)រៀល។



Scanned with CamScanner

៩-ការស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី៖

៩.១ ឈ្មោះ [redacted] សិទ្ធី ភេទប្រុស អាយុ ៣៨ឆ្នាំ សងប្រាក់ដើម ៨២,១៥០,០០០រៀល ជំងឺចិត្តនិងខាតបង់ពេលវេលាចំនួន ៨០,០០០,០០០រៀល។

៩.២ ឈ្មោះ [redacted] ស្រីគុណ ភេទស្រី អាយុ ២៨ឆ្នាំ សងប្រាក់ដើម ១៨,០០០,០០០រៀល និងប្រាក់ដុល្លារអាមេរិក ៣២០$ និងជំងឺចិត្ត ១០០០ដុល្លារអាមេរិក។

៩.៣ ឈ្មោះ [redacted] ផល្លា ភេទស្រី អាយុ ២៣ឆ្នាំ សងប្រាក់ដើម ២,៥០០ដុល្លារអាមេរិក និងជំងឺចិត្ត ៥០០ដុល្លារអាមេរិក។

៩.៤ ឈ្មោះ [redacted] ស៊ាវអេង ភេទស្រី អាយុ ២៩ឆ្នាំ សងប្រាក់ដើម ៤០,២៦០,៨២០រៀល និងជំងឺចិត្ត ១២,០០០,០០០រៀល។

៩.៥ ឈ្មោះ [redacted] តាវ៉ារុធ ភេទប្រុស កើតឆ្នាំ១៩៨៧ សងប្រាក់ដើម ៧០០០ដុល្លារអាមេរិក។

១០-ការសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ៖ តាមរយៈការពិភាក្សាដេញដោលនេះ នៅពេលសវនាការជាសាធារណៈចំនួនពីរលើកនេះ គឺបានឆ្លុះបញ្ចាំងឲ្យឃើញនូវការពិតមួយ ហើយការពិតនេះត្រូវបានលាតត្រដាងជាពិសេស ដោយសក្ខីកាមរបស់ដើមបណ្តឹងម្នាក់គឺឈ្មោះ [redacted] ស្រីគុណ។ បើទោះបីជាជនជាប់ចោទកន្លងមកតាំងពីតំណាក់កាលអយ្យការរហូតដល់ពេលសវនាការ ជនជាប់បានព្យាយាមឆ្លើយបង្វៀងយ៉ាងណាក៏ដោយប៉ុន្តែការពិតនៅតែជាការពិត។ ការពិតគឺនៅត្រង់ថា ជនជាប់ចោទក្នុងមុខរបរអាជីបរបស់ខ្លួនដែលជាអ្នកធ្វើការងារឲ្យគេ ទិញលុយ ដូរលុយ បានឆ្លៀតឪកាសនេះក្នុងការបោកប្រាស់ បុគ្គលផ្សេងដែលជាដៃគូររកស៊ីជាមួយជនជាប់ចោទដែលមានជាសមាជិកនៅក្នុងក្រុមបណ្តាយទំនាក់ទំនងសង្គមមួយហៅថា តេឡេក្រាម។ ជនជាប់ចោទបានប្រើប្រាស់ភាពងាយស្រួលក្នុងការងាររបស់ជនជាប់ចោទដើម្បីបោកប្រាស់ដៃគូររបស់ខ្លួនបានប្រាក់មួយចំនួនហើយការណ៍នោះឲ្យខូចផលប្រយោជន៍ទៅដល់ជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី ដែលជាដៃគូររកស៊ីជាមួយជនជាប់ចោទនាពេលកន្លងមក។ ឧបាយកលគឺថា ជនជាប់ចោទបានទំនាក់ទំនងធ្វើជាប្រតិបត្តិការដូរលុយដុចសព្វមួយដង ហើយដោយជនរងគ្រោះ ឬដៃគូរជនជាប់ចោទនោះ មានការរំពឹងទុកថា នឹងមានការចំណេញភាគលាភពី សកម្មភាពនៃការដោះដូរលុយ លុយខ្មែរ ដូរ លុយដុល្លារ លុយដុល្លារ ដូរ លុយខ្មែរ ក្នុងសកម្មភាពប្រតិបត្តិការរយៈពេលខ្លីៗ។ ហើយនៅពេលដែលបានលុយមកគឺជនជាប់ចោទបានយកប្រាក់នោះទៅប្រើប្រាស់ជាប្រយោជន៍ផ្ទាល់ខ្លួន រហូតមកដល់ថ្ងៃនេះ ជនជាប់ចោទពុំមានលទ្ធភាព មិនអាចរកប្រាក់សងទូទាត់ទៅឲ្យដៃគូររបស់ជនជាប់ចោទដែលមានការខូចខាតនោះទេ។ អំពើ ឬក៏សកម្មភាពរបស់ជនជាប់ចោទបានប្រព្រឹត្តនេះច្បាប់បានបញ្ញត្តិថាជាបទល្មើសឆបោក ដោយការប្រើឧបាយកលទុច្ចរិត ហើយនាំឲ្យខូចប្រយោជន៍របស់អ្នកដទៃហើយការឆបោកនេះមានកំណត់និយមន័យយ៉ាងជាក់លាក់នៅក្នុងមាត្រា៣៧៧ នៃក្រមព្រហ្មទណ្ឌ ដែលតម្រូវឲ្យផ្តន្ទាទោសដាក់ពន្ធនាគារតាមបញ្ញត្តិមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌដដែល គឺត្រូវដាក់ពន្ធនាគារចាប់ពី ៦ខែ ទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ពី ១,០០០,០០០រៀល ទៅ ៦,០០០,០០០រៀល។ សកម្មភាពដែលជនជាប់ចោទបានប្រព្រឹត្តនេះគឺចូលនៅក្នុងនិយមន័យបទល្មើសឆបោកដូចដែលបានលើកបង្ហាញ នៅក្នុងអង្គសវនាការ ជនជាប់ចោទ បានឆ្លើយដោះសារ ដែលថាសកម្មភាពដែលជនជាប់ចោទបានធ្វើនេះ គឺធ្វើឡើងក្នុងគោលបំណងដើម្បីជាប្រយោជន៍របស់បុគ្គលម្នាក់ផ្សេងទៀតដែលមានឈ្មោះ [redacted] ហារីសុន មានន័យថា ការអាក់ខានដែល



Scanned with CamScanner

ជនជាប់ចោទមិនអាចវេរប្រាក់ ឬផ្ញើប្រាក់ទៅឲ្យដៃគូររបស់ខ្លួនវិញនោះគឺដោយសារតែ [redacted] ហារីសុន មិនបាន ធ្វើការវេប្រាក់មកចូលក្នុងគណនីជនជាប់ចោទដើម្បីធ្វើការប្រើប្រាស់ដើម្បីឲ្យដៃគូជនជាប់ចោទភ្លាមៗ។ ចម្លើយ របស់ជនជាប់ចោទនេះគឺគ្រាន់តែជា លេសដោះសារគេចវេសពីការទទួលខុសត្រូវតែប៉ុណ្ណោះ មានចំណុចជា ច្រើនដែលបង្ហាញថាជនជាប់ចោទ មិនបានធ្វើសកម្មភាពនេះជាប្រយោជន៍ដល់បុគ្គលឈ្មោះ [redacted] ហារីសុន ទេ ហើយឈ្មោះ [redacted] ហារីសុន គឺមិនបានមានទំនាក់ទំនងពាក់ព័ន្ធទៅនឹងបទល្មើសឆបោក ដូចជនជាប់ចោទ ឈ្មោះ [redacted] ស្រីនិត នេះបានប្រព្រឹត្តនោះទេ។

ចំណុចទី១ តាមរយៈចម្លើយរបស់ដើមបណ្តឹងពីររូបគឺឈ្មោះ [redacted] ស្រីគុណ និងឈ្មោះ [redacted] ផល្លា បាន ឆ្លើយនាពេលសវនាការនេះយ៉ាងច្បាស់ថា ពួកគាត់ទាំងពីរនាក់ ក៏ជាអ្នកធ្លាប់ធ្វើការឲ្យឈ្មោះ [redacted] ហារីសុន ដែរ ប៉ុន្តែក្នុងប្រតិបត្តិការណ៍ ការងារនេះគឺ [redacted] ហារីសុន មានប្រាក់បម្រុងទុកគណនីរបស់បុគ្គលម្នាក់ៗ ដែល ជាបុគ្គលិកដែលធ្វើការឲ្យឈ្មោះ [redacted] ហារីសុន។ តួយ៉ាងគឺឈ្មោះ [redacted] ផល្លា នេះដើម្បីប្រើការក្នុងសកម្មភាព បំពេញការងារ ជាប្រយោជន៍ដល់ឈ្មោះ [redacted] ហារីសុន ក្នុងនាមជាថៅកែ និងកូនចៅ។ ក្នុងករណីដែលត្រូវមាន ប្រតិបត្តិការណ៍ដូរប្រាក់ទៅដៃគូរដែលមាននៅក្នុងក្រុមតេឡេក្រាមគឺបុគ្គលិករូបនេះ មានប្រាក់បម្រុងទុកក្នុង គណនីរៀងៗខ្លួនជាស្រេច ដើម្បីធ្វើសកម្មភាពទូទាត់តាមការព្រមព្រៀង មិនចាំបាច់ត្រូវ ដូរជាមួយដៃគូរ បាន បាញ់លុយមកហើយ ត្រូវបាញ់លុយទៅថៅកែ សោម ហារីសុន ហើយត្រូវឲ្យថៅកែ [redacted] ហារីសុន ត្រូវបាញ់ត្រ ឡប់មកវិញទេ ហើយបានបាញ់ទៅឲ្យដៃគូរវិញទេ។ ក្នុងសកម្មភាពការងារ ដែលឈ្មោះ [redacted] ស្រីគុណ និង យ៉ន ផល្លា បានឆ្លើយក្នុងទំនាក់ទំនងបែបនេះ គឺខុសពីការឆ្លើយអះអាងដោះសាររបស់ជនជាប់ចោទទាំងស្រុង។ ហេតុ ផលដែលជនជាប់ចោទឆ្លើយថា ដោយសារតែ [redacted] ហារីសុន បានលុដៃលឈ្មោះ [redacted] ស្រីនិត វេរទៅឲ្យ ហើយមិនបានវេរមកឲ្យ [redacted] ស្រីនិត វិញដើម្បីវេរទៅទូទាត់ទៅឲ្យដៃគូរនេះគឺជាការឆ្លើយភូតកុហក ដោះសារ ដើម្បីគេចវេសពីសកម្មភាពដែលជនជាប់ចោទបានប្រព្រឹត្ត។ ការប្រព្រឹត្តអំពើឆបោកនេះគឺឈ្មោះ [redacted] ស្រីនិត ជា អ្នកប្រព្រឹត្តដោយខ្លួនឯង និងទទួលខុសត្រូវដោយខ្លួនឯង បន្ទាប់ពីផ្ទុះរឿងនេះកើតឡើងឈ្មោះ [redacted] ហារីសុន បានលើកទឹកចិត្ត និងបាននាំជនរងគ្រោះទាំងឡាយទៅដាក់ពាក្យបណ្តឹងនៅសមត្ថកិច្ចអធិការដ្ឋាននគរបាល ហើយ [redacted] ហារីសុន បានបង្ហាញគ្រួសៗថា [redacted] ស្រីនិត មានបញ្ហាពាក់ព័ន្ធទៅនឹងការឡើងបញ្ជីឲ្យ [redacted] ហារីសុន រៀងរាល់ចុងខែមានការជំពាក់ប្រាក់ជាហូរហែរ។ ប្រសិនបើសកម្មភាពនេះធ្វើឡើងដោយការឆបោក សោម ហារីសុន នឹងមិនចេញមុខមកទទួលខុសត្រូវ និងដោះស្រាយ នាំជនរងគ្រោះទៅដាក់ពាក្យបណ្តឹងនោះទេ ហើយចំណុចនេះទៀតសោតក៏ផ្ទុយទៅនឹងអ្វីដែលជនជាប់ចោទបានឆ្លើយនៅពេលសវការនេះ ជនជាប់ចោទមិន ដែលបង្ហាញថា ពេលមានរឿងកើតឡើងឈ្មោះ [redacted] ហារីសុន មានវត្តមានចូលខ្លួនក្នុងការទទួលខុសត្រូវដោះ ស្រាយបញ្ហាជាមួយនឹងជនរងគ្រោះនោះទេគឺជនជាប់ចោទបានលាក់រឿងនេះ ប៉ុន្តែជនជាប់បានត្រឹមតែឆ្លើយ ដោះសារទម្លាក់ស្ថានភាពនេះទៅឲ្យ [redacted] ហារីសុន ដែលជាថៅកែរងគ្រោះជាមួយគ្នាដែរ។

ចំណុចទី២ នៅដំណាក់កាលស៊ើបសួរ ក៏ដូចជានៅសវនាការ ជនជាប់ចោទបានឆ្លើយទទួលស្គាល់ចំណុច ដែលថា បានយកលុយនៅក្នុងសកម្មភាពដែលជនជាប់ចោទបានប្រព្រឹត្តនោះយកទៅបម្រើឲ្យផលប្រយោជន៍ នូវការដោះទាល់បញ្ហាគ្រួសារ ដោះស្រាយជីវភាពគឺក្នុងមុខរបររកស៊ីជាដើម ត្រង់ចំណុចនេះបង្ហាញថា ដោយសារតែជនជាប់បានយកប្រាក់ទាំងនោះ ពីដៃគូររបស់ខ្លួន យកទៅប្រើការជាប្រយោជន៍ផ្ទាល់ខ្លួននេះហើយ



Scanned with CamScanner

មិនមានប្រាក់ណាដើម្បីយកទៅសងដៃគូររបស់ខ្លួនទេ។ ជនជាប់ចោទយកការងាររបស់ខ្លួនជាប្រចាំដោយមានការជួរលុយជាមួយដៃគូរ ដោយយកសកម្មភាពនេះដើម្បីធ្វើជាលេសមួយ ឆបោក យកប្រាក់ដៃគូរ ដែលជនជាប់ចោទធ្លាប់មានទំនាក់ទំនងជាមួយក្នុងការងារដោះដូរប្រាក់។ ត្រង់ចំណុចទី១ និងចំណុចទី២ ជាចំណុចសំខានដែលបានលាតត្រដាងឲ្យឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន។

ចំណុចទី៣ ជនជាប់ចោទតែងតែឆ្លើយថាបន្ទុក បំណុល សកម្មភាព គឺកើតឡើងដោយសារ [redacted] ហារីសុន មិនបានផ្ញើប្រាក់ទៅឲ្យដៃគូរ ប៉ុន្តែមានចំណុចមួយ ក្រោយពេលផ្ទុះរឿង [redacted] ផល្លា បង្ហោះនៅក្នុងក្រុមថា [redacted] ស្រីនិត បោកជាដើម ក៏កើតជារឿងជនរងគ្រោះទៅជួប [redacted] ស្រីនិត ដោះស្រាយ ព្យាយាមថា ធ្វើកិច្ចសន្យាសងប្រាក់ ត្រង់ចំណុចប្រសិនបើជាផលប្រយោជន៍ បានទៅលើ [redacted] ហារីសុន ឬអំពើនោះ គឺជាឧបាយកលរបស់ [redacted] ហារីសុន ហេតុអ្វីត្រូវ [redacted] ស្រីនិត ចេញមុខមកដោះស្រាយ ធ្វើកិច្ចសន្យាសងប្រាក់ ជាមួយនឹងដៃគូររបស់ខ្លួន។

ចំណុចទី៤ ចម្លើយដែលឈ្មោះ [redacted] ស្រីនិត បានឆ្លើយនៅប៉ូលីស ដោយសារតែបុគ្គលឈ្មោះ [redacted] ហារីសុន បង្គាប់ឲ្យឆ្លើយ ប៉ុន្តែក្រោយសាកសួរដើមបណ្តឹងទើបដឹងថា [redacted] ហារីសុន មានវត្តមានទាំងពេលនៅផ្ទះដែលត្រូវដោះស្រាយជាមួយជនរងគ្រោះ និងវត្តមាននៅអធិការដ្ឋានថែមទៀតផង។ ដើមបណ្តឹងថែមទាំងបានសួរជនជាប់ចោទថា តើលុយយកទៅណា ហើយមានជំពាក់លុយនរណាខ្លះ ដូច្នេះត្រង់ចំណុចនេះមិនមែនកន្លែងណាដែលថា [redacted] ហារីសុន បង្គាប់ឲ្យ [redacted] ស្រីនិត ឆ្លើយដាក់បន្ទុកលើខ្លួនឯងនោះទេ នេះគ្រាន់តែជាចម្លើយដោះសាររបស់ជនជាប់ចោទតែប៉ុណ្ណោះ។

ផ្អែកតាមអង្គហេតុ ចម្លើយផ្ទាល់របស់ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាសាក្សី និងភស្តុតាងផ្សេងៗ គឺតំណាងអយ្យការសូមតម្កល់ការចោទប្រកាន់ទុកជាបានការដដែល តប្បីតុលាការយកមកធ្វើការពិចារណា និងសម្រេចតាមការប្តឹងសុំរបស់តំណាងអយ្យការ។

១១-វត្ថុចាប់យករួមមាន៖ ទូរស័ព្ទម៉ាក IPhone ពណ៌ខៀវចំនួនមួយគ្រឿង (មិនប្រក្រតី) តប្បីតុលាការសម្រេចលើវត្ថុចាប់យកប្រគល់ឲ្យម្ចាស់ដើមវិញ។

១២-មេធាវីការពារក្តីឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋាន៖ កូនក្តីខ្លួនមិនបានប្រព្រឹត្តបទឆបោក ដូចការចោទប្រកាន់របស់តំណាងអយ្យការឡើយ ដោយហេតុថា៖ កង្វះធាតុផ្សំនៃបទល្មើស ភស្តុតាងមិនគ្រប់គ្រាន់ និងបុគ្គលផ្សេងជាអ្នកប្រព្រឹត្ត។ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២ និង នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២ ឈ្មោះ [redacted] ស្រីនិត ភេទស្រី អាយុ២២ឆ្នាំ ជនជាតិខ្មែរ ជាបុគ្គលិកវេរលុយ យីហោឈ្មោះ ឆោមឆាយ នៃក្រុមហ៊ុនទ្រូម៉ាន់នី ដែលមានទីតាំងនៅភូមិចុងបង្គោល ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល បានស្នើសុំប្តូរប្រាក់ពីខ្មែរទៅដុល្លារពីឈ្មោះ [redacted] **តារ៉ាវុធ** សរុបចំនួន ៤១.១៣០.០០០ (សែសិបមួយលានដប់បីម៉ឺន) រៀល (ឬ ស្មើនឹង ១០.០០០) ដុល្លារ តាមរយៈក្រុមតេឡេក្រាមមួយឈ្មោះ "សហគមន៍ទិញលក់លុយខ្មែរដុល្លារ" (ជាក្រុមទិញលក់ប្រាក់ពីខ្មែរទៅដុល្លារ ឬ ពីដុល្លារទៅខ្មែរ ដើម្បីចំណេញក្បាលកាក់សេនដែលមានសមាជិកជាច្រើនរយនាក់)។ នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២ ឈ្មោះ [redacted] ស្រីនិត បានស្នើដូរប្រាក់ពីដុល្លារទៅខ្មែរ ឬ ពីខ្មែរទៅដុល្លារ ក្នុងចំណោមសមាជិកក្រុមតេឡេក្រាមពីឈ្មោះ [redacted] **សិទ្ធី** ភេទប្រុស ចំនួន ៨២.១៥០.០០០ (ប៉ែតសិបពីរលានដប់ប្រាំម៉ឺន) រៀល និងឈ្មោះ [redacted] **ស៊ាវអេង** ភេទស្រី ចំនួន ៤០.៦២៨.២០០ (សែសិបលានហុកសិបពីរម៉ឺនប្រាំបីពាន់



Scanned with CamScanner

ពីររយ) រៀល។ ក្រៅពីទំនាក់ទំនងសមាជិកក្រុមគេឡេក្រាមខាងលើ ឈ្មោះ [redacted] ស្រីនិត បានខ្ចីប្រាក់ពី ឈ្មោះ [redacted] ស្រីគុណា ភេទស្រី ចំនួន ១៨.០០០.០០០ (ដប់ប្រាំលាន) រៀល និង ៣២០ (បីរយម្ភៃ) ដុល្លារ និងឈ្មោះ [redacted] ផល្លា ភេទស្រី ចំនួន ២.៥០០ (ពីរពាន់ប្រាំរយ) ដុល្លាអាមេរិក ដែលជាបុគ្គលិកធ្វើការឱ្យថៅកែវេរលុយ ឈ្មោះ [redacted] ហារីសុន ជាមួយគ្នា និងជាអ្នកគ្រប់គ្រងផ្ទាល់លើយីហោ ឈ្មោះ ឆោមឆាយ នៃក្រុមហ៊ុនទ្រូម៉ាន់នី របស់ជនជាប់ចោទ។

ក្រោយពីទទួលបានការផ្ទេរប្រាក់ពីឈ្មោះ [redacted] តារ៉ាវុធ ឈ្មោះ [redacted] សិទ្ធី និងឈ្មោះ [redacted] ស៊ាវអេង។ នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២ ឈ្មោះ [redacted] ស្រីនិត បានផ្ទេរប្រាក់ត្រឡប់ឱ្យឈ្មោះ [redacted] តារ៉ាវុធ ចំនួន ៣.០០០ (បីពាន់) ដុល្លារ នៃចំនួនទឹកប្រាក់សរុប ១០.០០០ (មួយម៉ឺន) ដុល្លារ ចំណែកឯ ឈ្មោះ [redacted] សិទ្ធី និង ឈ្មោះ [redacted] ស៊ាវអេង មិនបានផ្ទេរប្រាក់ត្រឡប់ឱ្យវិញទេ ដោយហេតុថាប្រាក់ទាំងអស់នេះ ឈ្មោះ [redacted] ស្រីនិត បានផ្ទេរចូលទៅក្នុងគណនីរបស់ ឈ្មោះ [redacted] ហារីសុន ដើម្បីឱ្យគាត់ដូរលុយពីខ្មែរទៅដុល្លារ ឬ ពីដុល្លារទៅខ្មែរ និងផ្ទេរត្រឡប់ឱ្យ ឈ្មោះ [redacted] ស្រីនិត វិញ ដើម្បីផ្ទេរប្រាក់បន្តទៅឱ្យឈ្មោះខាងលើ។ ប៉ុន្តែ ឈ្មោះ [redacted] ហារីសុន ក្រោយពីទទួលបានការផ្ទេរប្រាក់ពីឈ្មោះ [redacted] ស្រីនិត រួច ថៅកែរូបនេះមិនបានផ្ទេរប្រាក់ឱ្យដល់ ឈ្មោះ [redacted] ស្រីនិត ឡើយ។

ដោយរង់ចាំការផ្ទេរប្រាក់ត្រឡប់យូរពេក នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២ ឈ្មោះ [redacted] សិទ្ធី បានទាក់ទងមកឈ្មោះ [redacted] ស្រីនិត សួរនាំពីបញ្ហាការផ្ទេរប្រាក់នេះ ហើយ ឈ្មោះ [redacted] ស្រីនិត បានប្រាប់ថាខ្លួនកំពុងមានបញ្ហា និងឱ្យឈ្មោះ [redacted] សិទ្ធី មកកន្លែងវេរលុយដើម្បីដោះស្រាយ ដោយប្រាប់លេខទូរស័ព្ទ និងផ្ញើរទីតាំង (តាមតេឡេក្រាម) ផងដែរ។ នៅពេលមកដល់ទីតាំងវេរលុយ ឈ្មោះ [redacted] សិទ្ធី និង ឈ្មោះ [redacted] ស្រីនិត បានដោះស្រាយគ្នាមិនត្រូវ ហើយបាននាំ ឈ្មោះ [redacted] ស្រីនិត មកអធិការដ្ឋាននគរបាលស្រុក ដាក់ពាក្យបណ្តឹងប្តឹង ឈ្មោះ [redacted] ស្រីនិត និងបានឃាត់ខ្លួន និងឃុំខ្លួនបណ្តោះអាសន្នតាមនីតិវិធីផ្លូវច្បាប់។

មុនពេលតុលាការចាប់ផ្តើមការពិភាក្សាដេញដោលលើអង្គសេចក្តី មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានស្នើសុំឱ្យតុលាការចេញសាលក្រមចាត់របៀបដើម្បីស៊ើបសួរបន្ថែមទៅលើ ឈ្មោះ [redacted] ហារីសុន ដោយស្នើសុំឱ្យតុលាការកោះហៅបុគ្គលរូបនេះមកស្តាប់ចម្លើយ ឬ សួរតទល់គ្នា ដោយហេតុថាចម្លើយរបស់ជនជាប់ចោទនៅគ្រប់នីតិវិធីព្រហ្មទណ្ឌ ទាំងដំណាក់កាលចោទប្រកាន់ និងដំណាក់កាលស៊ើបសួរ បានបង្ហាញថា ឈ្មោះ [redacted] ហារីសុន មានទំនាក់ទំនងទៅនឹងការទទួលប្រាក់ពីជនជាប់ចោទដែលបានផ្ទេរពីជនរងគ្រោះមក ប៉ុន្តែឈ្មោះនេះមិនបានផ្ទេរប្រាក់ត្រឡប់មកឱ្យជនជាប់ចោទវិញ ដូច្នេះជនជាប់ចោទមិនមានប្រាក់ផ្ទេរទៅឱ្យជនរងគ្រោះវិញទេ។ ចំណែកឯ ភស្តុតាងជាទូរស័ព្ទដែលបានចាប់យក ក្នុងដំណាក់កាលស៊ើបសួរមិនមានភស្តុតាងជារបាយការណ៍ពីការពិនិត្យលើប្រតិបត្តិការផ្ទេរប្រាក់ចេញចូលរវាងជនជាប់ចោទ និង ឈ្មោះ [redacted] ហារីសុន ឡើយ បើទោះបីជាមានការស្នើសុំរបស់ជនជាប់ចោទក៏ដោយ។ ដូច្នេះការកំណត់ពីពិរុទ្ធភាពរបស់ជនជាប់ចោទពីបទឆបោកនៅមានវិមតិសង្ស័យនៅឡើយ។ ក្នុងការពិភាក្សាដេញដោលនៅពេលសវនាការបង្ហាញថា កូនក្តីខ្លួនមិនបានប្រព្រឹត្តបទឆបោក ដូចការចោទប្រកាន់របស់តំណាងអយ្យការឡើយដោយហេតុថា៖

-កង្វះធាតុផ្សំនៃបទល្មើស



Scanned with CamScanner

ជនជាប់ចោទមិនបានភូតកុហក និងប្រើកលល្បិចឱ្យជនរងគ្រោះផ្ទេរប្រាក់មកឱ្យខ្លួនឡើយ។ ប្រាក់ដែលជនជាប់ចោទទទួលបានពីជនរងគ្រោះ ឈ្មោះ [redacted] សិទ្ធី ឈ្មោះ [redacted] ស៊ាវអេង និងឈ្មោះ [redacted] តាវ៉ាវុធ ត្រូវបានផ្ទេរទៅក្នុងគណនីរបស់ ឈ្មោះ [redacted] ហារីសុន ហើយបុគ្គលនេះមិនបានផ្ទេរត្រឡប់មកឱ្យជនជាប់ចោទវិញឡើយ ដែលជាហេតុធ្វើឱ្យជនជាប់ចោទមិនមានប្រាក់ផ្ទេរត្រឡប់ឱ្យដល់ជនរងគ្រោះទាន់ពេលវេលា។ ចំពោះទំនាក់ទំនងនេះ ជនជាប់ចោទបានអះអាង និងបញ្ជាក់នៅគ្រប់ដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌ ព្រមទាំងដំណាក់កាលពិភាក្សាដេញដោលក្នុងពេលសវនាការផងដែរ។

យោង "**កំណត់ហេតុសួរចម្លើយ**" ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២២ (បន្ទាត់ទី៨ នៃទំព័រទី២) និង "ដីកាសន្និដ្ឋានស្ថាពរ" លេខៈ ៣១៤ ដកសព/២៣ (បន្ទាត់ទី១៧ ដល់ ទី២១ នៃទំព័រទី៤) របស់តំណាងអយ្យការ ជនជាប់ចោទបានឆ្លើយដូចគ្នាថា "លុយដែលនាងខ្ញុំដោះដូរជាមួយអ្នកនៅក្នុងក្រុម ហើយពុំទាន់បានវេរទៅជនរងគ្រោះទាំងបួននាក់វិញ គឺសរុបទាំងអស់ $ ៣២.៦២០ (បីម៉ឺនពីរពាន់ប្រាំមួយរយម្ភៃ) ដុល្លារអាមេរិក និងលុយខ្មែរចំនួន ១៨ លានរៀល ពីមនុស្សចំនួន ០៤ នាក់ឈ្មោះ [redacted] ផល្លា ភេទស្រី ឈ្មោះ [redacted] សិទ្ធី ភេទប្រុស ឈ្មោះ [redacted] ស្រីគុណា ភេទស្រី និងឈ្មោះ [redacted] ស៊ាវអេង ភេទស្រី លុយនោះខ្ញុំយកទៅទូទាត់ជាមួយថៅកែ"។

យោង "**កំណត់ហេតុស្តីពីការសួរចម្លើយជនត្រូវចោទ**" ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២២ (បន្ទាត់ទី២១ ដល់ ទី៤៤ នៃទំព័រទី២ និងទី៣) ជនជាប់ចោទបានឆ្លើយថា "ក្រោយពីទទួលលុយហើយ ខ្ញុំបានវេរលុយនេះទៅឱ្យថៅកែ ឈ្មោះ [redacted] ហារីសុន រួចរាល់អស់ហើយ។ នាងខ្ញុំសូមបញ្ជាក់ថាលុយដែលវេរមកតាមរយៈខ្ញុំតែម្នាក់ឯងទេ ហើយនាងខ្ញុំវេរទៅឱ្យថៅកែតែមួយឈ្មោះ គឺឈ្មោះ [redacted] ហារីសុន ទាំងអស់។ របាយការណ៍ដែលនាងខ្ញុំទទួលបានប្រាក់លើអ្នកទាំងបួន និងវេរប្រាក់ទៅឱ្យថៅកែ គឺនៅទូរស័ព្ទ ១៣ Pro max ដែលបានដកហូតពីរូបនាងខ្ញុំ។ នាងខ្ញុំសូមបញ្ជាក់ថា នៅពេលប្រគល់ប្រាក់ទៅម្ចាស់ដើមវិញ គឺថៅកែគាត់មានភារកិច្ចផ្ទេរប្រាក់ចូលកុងខ្ញុំ ហើយនាងខ្ញុំវេរសាច់ប្រាក់ទៅឱ្យម្ចាស់ដើម។ ប៉ុន្តែពេលនោះ គឺថៅកែអត់បានវេរលុយចូលកុងនាងខ្ញុំ នេះជាមូលហេតុនាងខ្ញុំអត់លុយវេរបន្តទៅឱ្យម្ចាស់លុយ ទាំងបួននាក់។"

យោង "**កំណត់ហេតុស្តីពីការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី**" ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២ មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី (បន្ទាត់ទី១៨ ដល់ ២៨ នៃទំព័រទី២) ឆ្លើយថា "យោងតាមចម្លើយ ហ៊ន ស្រីនិត ឃើញថាមានការពាក់ព័ន្ធ ឈ្មោះ [redacted] ហារីសុន ដូច្នេះបុគ្គលទាំងពីរនេះអាចកំណត់ជាក្រុមតែមួយក្នុងការប្រព្រឹត្តសកម្មភាពឆបោកនេះ។ ដូចនេះស្នើសុំតុលាការធ្វើការកោះហៅ ឈ្មោះ [redacted] ហារីសុន មកបំភ្លឺក្នុងករណីនេះ និងសុំឱ្យតុលាការធ្វើការចោទប្រកាន់លើឈ្មោះនេះតាមផ្លូវច្បាប់។"

យោង "**ដីកាដំណោះស្រាយ**" សំណុំរឿងស៊ើបសួរលេខៈ ១១៣០ សស ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២២ លេខៈ៣២០/២៣ (កថាខណ្ឌទី១ នៃវាក្យខណ្ឌទី២ ចំនុចទី២ នៃផ្នែកសំអាងហេតុ) ចៅក្រមស៊ើបសួរយល់ឃើញថា "នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីបានវេរលុយដោះដូរមកខ្លួនក្នុងគ្រុបនោះ ខ្លួនពុំបានវេរឱ្យត្រឡប់ទៅវិញឡើយ ដោយខ្លួនបានយកលុយទៅទូទាត់ជាមួយថៅកែ"។

នៅក្នុងដំណាក់កាលពិភាក្សាដេញដោល ជនជាប់ចោទបានឆ្លើយថា ខ្លួនបានទទួលការផ្ទេរប្រាក់ពីដើម បណ្តឹងរដ្ឋប្បវេណី ប្រាកដមែន ប៉ុន្តែប្រាក់ដែលបានទទួលនេះ ជនជាប់ចោទបានផ្ទេរប្រាក់ទៅឱ្យ ឈ្មោះ [redacted] ហារីសុន ដែលជាថៅកែរបស់ខ្លួន ហើយបុគ្គលនេះមិនបានផ្ទេរប្រាក់ត្រឡប់ឱ្យខ្លួនវិញឡើយ ដូច្នេះខ្លួនមិនប្រាក់



Scanned with CamScanner

ដើម្បីផ្ទេរបន្តឱ្យដល់ម្ចាស់ដើម។ ចំពោះឈ្មោះ [redacted] ស្រីគុណ និងឈ្មោះ [redacted] ផល្លា ជនជាប់ចោទឆ្លើយថា ខ្លួនបានខ្ចីពីពួកគេដែលជាបុគ្គលិកធ្វើការឱ្យថៅកែដូចគ្នា។

យោងតាមពាក្យបណ្ដឹងរបស់ឈ្មោះ [redacted] ស្រីគុណ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២ និងឈ្មោះ [redacted] ផល្លា ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២ ប្ដឹងទៅអធិការដ្ឋាននគរបាលស្រុកអង្គស្នួលបានអះអាងថា ជនជាប់ចោទបានខ្ចីប្រាក់ពីពួកគេ។ ការអះអាងនេះមានភាពស៊ីសង្វាក់គ្នានៅក្នុងកំណត់ហេតុ ស្ដីពីការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២២ របស់ ឈ្មោះ [redacted] ស្រីគុណ បានឆ្លើយថា "នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោងប្រហែល ១២ ថ្ងៃត្រង់ជាង ឈ្មោះ [redacted] ស្រីនិត ឆាតតាមមេសសិនជើរ សុំខ្ចីលុយ ១៨ លាន រៀលនៅម៉ោងប្រហែល ១២ ថ្ងៃត្រង់" និង កំណត់ហេតុស្ដីពីការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២២ របស់ ឈ្មោះ [redacted] ផល្លា បានឆ្លើយថា "នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង៧ និង២០ នាទី ពេលឈ្មោះ [redacted] ស្រីនិត បានឆាតតាមតេឡេក្រាមសុំខ្ចីលុយនាងខ្ញុំចំនួន ២.៥០០ ដុល្លារ បន្ទាប់មកនាងខ្ញុំបានបាញ់ទឹកប្រាក់ទៅលេខគណនី ២៤០១៣២២៣ ឈ្មោះ [redacted] ស្រីនិត"។

ដូច្នេះទំនាក់ទំនងរវាង ឈ្មោះ [redacted] ស្រីគុណ ឈ្មោះ [redacted] ផល្លា និងជនជាប់ចោទ គឺជាទំនាក់ទំនងឯកជនដែលកើតចេញពីកិច្ចសន្យាខ្ចីប្រាក់ និងត្រូវគ្រប់គ្រងដោយទំនាក់ទំនងគតិយុត្តផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី ដែលមិនមែនជាបទល្មើសព្រហ្មទណ្ឌឡើយ។

យោងតាមការពិភាក្សាដេញដោលក្នុងពេលសវនាការ និងការពិនិត្យកំណត់ហេតុនិងភស្តុតាងក្នុងសំណុំរឿងនេះ បង្ហាញថា ជនជាប់ចោទមិនបានប្រើប្រាស់ឧបាយកលទុច្ចរិត ដោយភូតកុហក និងប្រើល្បិចកលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីឱ្យពួកគេផ្ទេរប្រាក់មកឱ្យខ្លួនឡើយ។ ប្រាក់ដែលទទួលបានពីដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានផ្ទេរទៅ ឈ្មោះ [redacted] ហារីសុន ដែលជាអ្នកគ្រប់គ្រងផ្ទាល់ និងជាថៅកែរបស់ខ្លួន។ ចំពោះធាតុអត្តនោម័តនៃអំពើបទឆបោក ជនជាប់ចោទមិនមាននោះទេ ដោយហេតុថា តាមពាក្យបណ្ដឹង និងកំណត់ហេតុស្ដាប់ការបំភ្លឺរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សិទ្ធី និងឈ្មោះ [redacted] ស៊ាវអេង ជនជាប់ចោទបានប្រាប់លេខទូរស័ព្ទ ផ្ញើទីតាំងកន្លែងវេរលុយ និងបានហៅភាគីពាក់ព័ន្ធមកដោះស្រាយផងដែរ។ ជនជាប់ចោទបានផ្ញើរប្រាក់ឱ្យឈ្មោះ [redacted] តារ៉ាវុធ ចំនួន ៣.០០០ ដុល្លារ ត្រឡប់វិញនៅថ្ងៃកើតហេតុនោះផងដែរ។ ប្រសិនបើ ជនជាប់ចោទមានចេតនាទុច្ចរិត និងគេចវេះមិនចូលរួមដោះស្រាយនោះទេ នៅថ្ងៃកើតហេតុនោះ ជនជាប់ចោទប្រាកដជារត់គេចខ្លួនបាត់ ដោយមិនផ្ដល់លេខទូរសព្ទ័ ទីតាំងកន្លែងការងារ និងឱ្យដើមបណ្ដឹងរដ្ឋប្បវេណីមកចូលរួមដោះស្រាយឡើយ។

-ភស្តុតាងមិនគ្រប់គ្រាន់

ក្នុងសំណុំរឿងព្រហ្មទណ្ឌនេះ ភស្តុតាងដាក់បន្ទុកគឺមានតែពាក្យបណ្ដឹងរបស់ជនរងគ្រោះ សាក្សីរបស់ជនរងគ្រោះ ភស្តុតាងជាឯកសារផ្ដល់ដោយជនរងគ្រោះ និងចម្លើយរបស់ជនជាប់ចោទតែប៉ុណ្ណោះ។ ចំពោះភស្តុងតាងផ្សេងទៀតដែលគាំទ្រដល់ការចោទប្រកាន់នេះ ការស៊ើបសួរបានធ្វើតែចំពោះក្រុមហ៊ុនទ្រូម៉ាន់នីខេមបូឌាតែមួយគត់ ចំណែកឯក្រុមហ៊ុនផ្សេងទៀត (ធនាគារ អេ ប៊ី អេ ធនាគារ ស្ថាបនា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ឃេ និងក្រុមហ៊ុន វីន ជាអាទិ៍) ដែលមានទំនាក់ទំនងចំពោះប្រតិបត្តិការនៃការផ្ទេរប្រាក់ចេញចូលរវាងជនជាប់ចោទ និងជនរងគ្រោះ មិនបានធ្វើការស៊ើបសួរឡើយ។



Scanned with CamScanner

ចំពោះការស៊ើបសួរដោះបន្ទុកជនជាប់ចោទមិនបានធ្វើឡើយ បើទោះបីជាជនជាប់ចោទ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងមេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី បានស្នើសុំឱ្យកោះហៅសាកសួរឈ្មោះ [redacted] ហារីសុន ដែលជាបុគ្គល សង្ស័យពាក់ព័ន្ធទៅនឹងប្រតិបត្តិការផ្ទេរប្រាក់ចេញចូលនេះ និងជាបុគ្គលសំខាន់ដែលជនជាប់ចោទអះអាងថាបានផ្ទេរប្រាក់ទាំងអស់ទៅឱ្យ ក្រោយពីទទួលបានការផ្ទេរប្រាក់ពីដើមបណ្តឹងរដ្ឋប្បវេណី។ ការស្នើសុំឱ្យកោះហៅដោយភាគីពាក់ព័ន្ធចំពោះ ឈ្មោះ [redacted] ហារីសុន នេះត្រូវបានធ្វើឡើងនៅដំណាក់កាលចោទប្រកាន់ និងដំណាក់កាលស៊ើបសួរ ប៉ុន្តែបុគ្គលរូបនេះមិនបានទទួលការកោះហៅឡើយ។ នៅមុនពេលពិភាក្សាដេញដោលលើអង្គសេចក្តី មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទក៏បានស្នើឱ្យចៅក្រមជំនុំជម្រះ ចេញសាលក្រមចាត់វិធានដើម្បីស៊ើបសួរបន្ថែម ដោយកោះហៅបុគ្គលដែលមានការសង្ស័យខាងលើនេះដែរ ប៉ុន្តែតុលាការមិនសម្រេចតាមការស្នើសុំឡើយ។

ចំពោះសាក្សីរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី គឺជាសាក្សីដែលមិននៅកន្លែងកើតហេតុ ដឹងតាមរយៈការផ្តល់ព័ត៌មានរបស់ដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ៖ ១.យោងតាមកំណត់ហេតុស្តាប់ចម្លើយសាក្សីឈ្មោះ [redacted] **កែវពិសិដ្ឋ** ភេទប្រុស ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២ បានឆ្លើយថា "ខ្ញុំបាទបានដឹងរឿងខាងលើដោយសារតែឈ្មោះ [redacted] សិទ្ធី គេមកខ្ញុំហើយឲខ្ញុំជូនទៅបែកចាន បន្ទាប់មកខ្ញុំបានសួរទៅវិញថាទៅបែកចានធ្វើអ្វី ពេលនោះឈ្មោះ [redacted] សិទ្ធី ក៏បានប្រាប់ខ្ញុំថាបានចាញ់បោកគេនៅបែកចានអស់ប្រាក់ ៨២,១៨០,០០០ (ប៉ែតសិបពីរលានដប់ប្រាំបីម៉ឺន) រៀល ក្រៅពីនេះអ្វីផ្សេងទៀតគឺខ្ញុំមិនដឹងនោះទេ។ ២.យោងតាមកំណត់ហេតុស្តាប់ចម្លើយសាក្សីឈ្មោះ [redacted] **ពុទ្ធលី** ភេទស្រី ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២២ បានឆ្លើយថាពេល "នាងខ្ញុំកំពុងដេកចុចទូរស័ព្ទក្នុងបន្ទប់ស្រាប់តែ ឈ្មោះ [redacted] ស៊ាវអេង ឆាតមកសួរថាមានឃើញគេដាក់លុយចំនួន ៩៨.០០០ (ប្រាំបួនពាន់ប្រាំបីរយ) ដុល្លារអាមេរិក មកឲអត់ខ្ញុំក៏ឆ្លើយថាអត់ឃើញទេ។" និង ៣.យោងតាមកំណត់ហេតុស្តាប់ចម្លើយសាក្សីឈ្មោះ [redacted] **សូរីណែត** ភេទស្រី ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២ បានឆ្លើយថា "នាងខ្ញុំបានឃើញឈ្មោះ [redacted] ស្រីគុណ បានឲប្រាក់ទៅ ឈ្មោះ [redacted] ស្រីនិត ខ្ចីចំនួន ១៨.០០០.០០០ (ដប់ប្រាំបីលាន) និង $៣២០ ចំពោះប្រាក់នេះនាងខ្ញុំបានឃើញ តាមរយៈតេឡេក្រាមមិនបានឃើញប្រាក់ផ្ទាល់ទេឃើញតែវិក្កយបត្រចំនួនប្រាក់តាមតេឡេក្រាម រឿងអ្វីផ្សេងទៀតខ្ញុំមិនដឹងនោះទេ។

ដូច្នេះចំពោះការចោទប្រកាន់នេះមិនមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ដើម្បីកំណត់អត្ថិភាពនៃបទល្មើសចំពោះជនជាប់ចោទឡើយ គឺមានតែពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី សាក្សីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ភស្តុតាងជាឯកសារផ្តល់ដោយដើមបណ្តឹងរដ្ឋប្បវេណី និងចម្លើយរបស់ជនជាប់ចោទតែប៉ុណ្ណោះ ចំណែកឯភស្តុតាងផ្សេងទៀតដែលមានទំនាក់ទំនងទៅនឹងប្រតិបត្តិការផ្ទេរប្រាក់នេះ ការស៊ើបសួរមិនបានធ្វើឡើយ។ ឈ្មោះ [redacted] ហារីសុន ដែលជាបុគ្គលសង្ស័យពាក់ព័ន្ធបទល្មើសនេះមិនបានកោះហៅមកសាកសួរ ដែលជាបុគ្គលសំខាន់ដែលអាចបញ្ជាក់បានពីអត្ថិភាពនៃបទល្មើសនេះ ទោះបី ជាមានការស្នើសុំពីជនជាប់ចោទ មេធាវីការពារជនជាប់ចោទ និងមេធាវីការពាសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ។ ជាគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។ តាមមាត្រា៣៨ កថាខណ្ឌទី៥ ចែងថា វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ" និង មាត្រា៣៥១ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌបញ្ញត្តិថា វិមតិសង្ស័យត្រូវតែបានជា" អត្ថប្រយោជន៍ដល់ជនជាប់ចោទជានិច្ច។



Scanned with CamScanner

-អ្នកប្រព្រឹត្តជាអ្នកដទៃ

នៅក្នុងអង្គហេតុនេះ គឺបុគ្គលផ្សេងជាអ្នកប្រព្រឹត្តបទឆបោក មិនមែនជនជាប់ចោទទេ។ បុគ្គលដែលសង្ស័យគឺ ឈ្មោះ [redacted] ហារីសុន ដែលជាថៅកែរបស់ជនជាប់ចោទ។ នៅក្នុងផ្នែកសំអាងហេតុនៃដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរបានយល់ឃើញដែលថា "នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីបានវេរលុយដោះដូរមកខ្លួនក្នុងគ្រុបនោះ ខ្លួនពុំបានវេរឱ្យត្រឡប់ទៅវិញឡើយ ដោយខ្លួនបានយកលុយទៅទូទាត់ជាមួយថៅកែ"។ ការឆ្លើយរបស់ជនជាប់ចោទចំពោះទំនាក់ទំនងផ្ទេរប្រាក់នេះ គឺមានភាពស៊ីសង្វាក់គ្នា ដោយហេតុថា នៅពេលការពិភាក្សាដេញដោលលើកទី០២ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៣ ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សិទ្ធី បានឆ្លើយ និងបញ្ជាក់ភស្តុតាងជាទូរសព្ទថា "ខ្ញុំធ្លាប់ទទួលបានការផ្ទេរប្រាក់ពីឈ្មោះ [redacted] ហារីសុន ប្រហែល ០៥ ទៅ ០៦ លើកផងដែរ ដែលកើតចេញពីទំនាក់ទំនងរវាងខ្ញុំ និងជនជាប់ចោទ"។

រឿងក្តីនេះពិតណាស់ គឺបុគ្គលផ្សេងជាអ្នកប្រព្រឹត្ត។ តាមចម្លើយរបស់កូនក្តីខ្ញុំនៅដំណាក់កាលអយ្យការ និងស៊ើបសួរបានឆ្លើយយ៉ាងជាក់ច្បាស់ថា ខ្លួនមានភស្តុតាងបញ្ជាក់នៅក្នុងទូរស័ព្ទ 13 Pro max ពីប្រតិបត្តិការផ្ទេរប្រាក់ពីខ្លួនទៅឈ្មោះ [redacted] ហារីសុន ហើយឈ្មោះនេះមិនបានផ្ទេរប្រាក់ឱ្យខ្លួន ដើម្បីផ្ទេរត្រឡប់ទៅដើមបណ្តឹងរដ្ឋប្បវេណីឡើយ ទោះបីជាមានការដាក់ពាក្យស្នើសុំទូរស័ព្ទ 13 Pro max ទៅតុលាការ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ ២០២២ ក៏ដោយ តុលាការមិនបានប្រគល់ទូរស័ព្ទត្រឡប់វិញ និងមិនបានស៊ើបអង្កេតលើប្រតិបត្តិការរវាងជនជាប់ចោទ និង ឈ្មោះ [redacted] ហារីសុន ឡើយ។

-សេចក្តីសន្និដ្ឋាន និងសំណូមពរ

ផ្អែកលើអង្គហេតុ អង្គច្បាប់ ភស្តុតាងក្នុងសំណុំរឿង និងការពិភាក្សាដេញដោលចំនួនពីរលើក។ ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] ស្រីនិត សូមធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្លួនមិនបានប្រព្រឹត្តបទល្មើសតាមការចោទប្រកាន់របស់តំណាងអយ្យការឡើយ ដោយហេតុថារឿងក្តីនេះកង្វះធាតុផ្សំនៃបទល្មើស ភស្តុតាងមិនគ្រប់គ្រាន់ និងបុគ្គលផ្សេងជាអ្នកប្រព្រឹត្ត និងសូមសំណូមពរឱ្យ ឯកឧត្តមប្រធាន មេត្តាសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទ និងប្រគល់វត្ថុដែលចាប់យកវិញ។

-ចំពោះការស្នើសុំរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទពេលសវនាការបានយល់ឃើញដូចក្នុងសំអាងហេតុខាងលើនៃសាលក្រមនេះ។

១៣-ជនជាប់ចោទបានសំណូមពរៈ សូមឲ្យតុលាការលើកលែងបទចោទមកលើខ្លួន ហើយស៊ើបសួរលើ [redacted] ហារីសុន ព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ គប្បីតុលាការពិចារណាលើការស្នើរសុំរបស់ជនជាប់ចោទ។

## ហេតុដូច្នេះ សាលាដំបូងខេត្តកណ្តាល

## វិនិច្ឆ័យសេចក្តី

១-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **ស្រីនិត** ភេទស្រី អាយុ ២២ឆ្នាំ សញ្ជាតិខ្មែរ (មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារ កំណត់រយៈពេល **០១(មួយ)ឆ្នាំ**



Scanned with CamScanner

ពីបទ៖ **ឆបោក** ប្រព្រឹត្តនៅភូមិចុងបង្គោល ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្ដាល កាលពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២ បទល្មើសដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិ**មាត្រា៣៧៧ និងមាត្រា៣៧៨** នៃក្រមព្រហ្មទណ្ឌ។

២.បង្គាប់ឲ្យជនជាប់ចោទ សងសំណងព្យាសនកម្ម និងជំងឺចិត្តដល់ដើមបណ្ដឹងរដ្ឋប្បវេណី៖

២.១ សងសំណងព្យសនកម្មទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សិទ្ធី** ប្រាក់ដើមចំនួន ៨២,១៥០,០០០(ប៉ែតសិបពីរលានមួយសែនប្រាំម៉ឺន)រៀល និងជំងឺចិត្ត ២០,០០០,០០០(មួយម្ភៃលាន)រៀល ការទាមទារលើសពីនេះបដិសេធចោល។

២.២ សងសំណងព្យសនកម្មទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ស្រីគុណ** ប្រាក់ដើមចំនួន ១៨,០០០,០០០(ដប់ប្រាំបីលាន)រៀល និងប្រាក់ដើម៣២០$(បីរយម្ភៃ)ដុល្លាអាមេរិក និងជំងឺចិត្ត ៤,០០០,០០០(បួនលាន)រៀល ការទាមទារលើសពីនេះបដិសេធចោល។

២.៣ សងសំណងព្យសនកម្មទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ផល្លា** ប្រាក់ដើមចំនួន២៥០០$(ពីរពាន់ប្រាំរយ)ដុល្លារអាមេរិក និងជំងឺចិត្ត ២,០០០,០០០(ពីរលាន)រៀល ការទាមទារលើសពីនេះបដិសេធចោល។

២.៤ សងសំណងព្យសនកម្មទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ស៊ាវអេង** ប្រាក់ដើមចំនួន ៤០,២៦៨,២០០(សែសិបលានពីរសែនប្រាំមួយម៉ឺនប្រាំបីពាន់ពីររយ)រៀល និងជំងឺចិត្ត ៨,០០០,០០០(ប្រាំបីលាន)រៀល ការទាមទារលើសពីនេះបដិសេធចោល។

២.៥ សងសំណងព្យសនកម្មទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **តាវ៉ាវុធ** ប្រាក់ដើមចំនួន ៧,០០០$(ប្រាំពីរពាន់)ដុល្លារអាមេរិក ការទាមទារលើសពីនេះបដិសេធចោល។

៣-វត្ថុចាប់យករួមមាន៖ ទូរស័ព្ទម៉ាក IPhone ពណ៌ខៀវចំនួនមួយគ្រឿង (មិនប្រក្រតី) តុលាការសម្រេចប្រគល់ឲ្យម្ចាស់ដើមវិញ។

សាលក្រមនេះជំនុំជម្រះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ស្រីនិត ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សិទ្ធី ឈ្មោះ [redacted] ស្រីគុណ ឈ្មោះ [redacted] ផល្លា និងឈ្មោះ [redacted] ស៊ាវអេង និងកំបាំងមុខដើមបណ្ដឹងដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] តាវ៉ាវុធ។

-ទុកសិទ្ធិឲ្យប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខា និងត្រា ៖ [redacted]

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា ៖ [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ១៥កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

កណ្ដាល, ថ្ងៃទី០១ ខែសីហា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned with CamScanner